## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅរបាយការណ៍

# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ

# ខេត្តព្រៃវែង



*ផលិតដោយៈ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ*

*វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ*

**រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២២**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅរបាយការណ៍

# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ

## ខេត្តព្រៃវែង

*ផលិតដោយ៖ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ*

*វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ*

**រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២២**

# មាតិកា


**បុព្វកថា** .......... I

**អារម្ភកថា** .......... II

**ជំពូកទី១** .......... ១

**សេចក្តីផ្តើម** .......... ១

**១.១. សេចក្តីផ្តើម** .......... ២

*១.១.១. និមិត្តសញ្ញាសម្គាល់* .......... ៤

*១.១.២. ផែនទីខេត្តព្រៃវែង* .......... ៥

*១.១.៣. ផែនទីខេត្តដែលបានអនុវត្តគម្រោង* .......... ៦

**១.២. គោលបំណង** .......... ៦

**១.៣. វិធីសាស្ត្រប្រមូលទិន្នន័យ** .......... ៧

**១.៤. ការផលិតទិន្នន័យ** .......... ៧

**ជំពូកទី២** .......... ៨

**វិភាគទិន្នន័យ** .......... ៨

**២.១. ព័ត៌មានប្រជាសាស្ត្រ** .......... ៩

*២.១.១. ព័ត៌មានគ្រួសារ* .......... ៩

*២.១.២. ព័ត៌មានប្រជាជន* .......... ១៣

*២.១.៣. ការផ្លាស់ប្តូរទីលំនៅ* .......... ១៦

*២.១.៤. លំនៅឋាន* .......... ២០

*២.១.៥. បរិក្ខារកសិកម្ម ដឹកជញ្ជូន និងប្រើប្រាស់* .......... ២៧

**២.២. អត្រាកំណើត និងមរណភាព** .......... ៣០

*២.២.១. អត្រាកំណើត* .......... ៣០

*២.២.២. មរណភាព* .......... ៣២

**២.៣. ពិការភាព និងបុគ្គលគ្មានអ្នកថែទាំ** .......... ៣៥

**២.៤. អាពាហ៍ពិពាហ៍ និងការលែងលះ** .......... ៤២

**២.៥. ការប្រើប្រាស់ទឹក និងអនាម័យ** .......... ៤៣

**២.៦. បរិស្ថាន និងធនធានធម្មជាតិ** .......... ៤៧

**២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច** .......... ៥០

*២.៧.១. សន្តិសុខសង្គម* .......... ៥០

*២.៧.២. សេដ្ឋកិច្ចគ្រួសារ ...................................................... ៥២*
*២.៧.៣. សកម្មភាពនៃការអភិវឌ្ឍ ...................................................... ៥៦*
**២.៨. វិស័យអប់រំ និងសេវាសង្គម ...................................................... ៥៧**
*២.៨.១. វិស័យអប់រំ ...................................................... ៥៧*
*២.៨.២. សេវាសង្គម ...................................................... ៥៩*
**២.៩. ផ្លូវគមនាគមន៍ ...................................................... ៦០**
**២.១០. សុខាភិបាល ...................................................... ៦០**
*២.១០.១. សេវាកម្មសុខភាព ...................................................... ៦០*
*២.១០.២. ជំងឺសំខាន់ៗ ...................................................... ៦៣*
*២.១០.៣. ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ និងកុមារកំព្រា ...................................................... ៦៥*
**២.១១. កសិកម្ម ...................................................... ៦៧**
*២.១១.១. ការកាន់កាប់ដីកសិកម្ម ...................................................... ៦៧*
*២.១១.២. ប្រភេទផ្ទៃដីកសិកម្ម ...................................................... ៦៨*
*២.១១.៣. ផ្ទៃដីកសិកម្ម និងផលិតកម្ម ...................................................... ៦៩*
*២.១១.៤. ប្រព័ន្ធស្រោចស្រព ...................................................... ៦៩*
*២.១១.៥. ការប្រើប្រាស់ជី និងថ្នាំពុលលើផ្ទៃដីផលិតកម្ម ...................................................... ៧១*
*២.១១.៦. ការចិញ្ចឹមបសុសត្វ និងបសុបក្សី ...................................................... ៧២*
*២.១១.៧. ទិន្នផលដំណាំ និងគោលបំណងផលិត ...................................................... ៧៥*
**ជំពូកទី៣ ...................................................... ៧៧**
**សន្និដ្ឋាន និងអនុសាសន៍ ...................................................... ៧៧**
**៣.១. សន្និដ្ឋាន ...................................................... ៧៨**
**៣.២. អនុសាសន៍ ...................................................... ៧៨**
**តារាងទិន្នន័យសង្ខេប ...................................................... ៧៩**
**តារាងកម្រងបញ្ជីសំណួរស្ថិតិថ្នាក់ក្រោមជាតិ ...................................................... ១០០**

# បុព្វកថា

មានសេចក្តីសោមនស្សរីករាយ នឹងបង្ហាញជូននូវរបាយការណ៍លទ្ធផលវិភាគ ស្តីពី "ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ" ជំហានទី៦ ដោយផ្អែកលើទិន្នន័យដែលបានប្រមូលចំនួន ១ខេត្ត គឺខេត្តព្រៃវែង។ នៅក្នុងរបាយការណ៍នេះមានទិន្នន័យសំខាន់ៗជារួមៈ ស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការកសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចឱ្យក្រសួងផែនការបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនេះឡើងតាមអនុក្រឹត្យ លេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ កន្លងមក ។

សូមថ្លែងអំណរគុណដល់ ឯកឧត្តម **ហោ ដារិទ្ធ** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំ និងសម្របសម្រួលការងារនេះតាំងពីចាប់ផ្តើម ដោយមានជំនួយការពីឯកឧត្តមបណ្ឌិត **ម៉េង គីមហ៊ី** និងឯកឧត្តម **ពេជ ពោធិ** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ឯកឧត្តម **ចាន់ សំអាត** ប្រធាននាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ លោក លោកស្រី អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីទាំងអស់ដែលនៅក្នុងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ឯកឧត្តមប្រធានមន្ទីរផែនការ និងសហការីនៃខេត្តព្រៃវែង ដែលបានជួយសហការយ៉ាងសកម្មនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យជាក់ស្តែង។

ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា អ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការសម្រាប់អភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ នឹងប្រើប្រាស់របាយការណ៍លទ្ធផលវិភាគ ស្តីពី "ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ" ជំហានទី៦ ដ៏មានសារៈសំខាន់មួយនេះ។៚

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

ភ្នំពេញ កម្ពុជា
ខែធ្នូ ឆ្នាំ២០២២

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

ការបោះពុម្ពផ្សាយសៀវភៅលើកទី៦ នៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដែលបានផលិតឡើងដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការសហការពីមន្ទីរផែនការខេត្តព្រៃវែង។ សៀវភៅនេះផ្តល់នូវទិន្នន័យសំខាន់ៗមួយចំនួនរួមមានៈ ស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម ដែលជាសូចនាករដ៏សំខាន់មិនអាចខ្វះបានសម្រាប់កសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ។

នៅក្នុងសៀវភៅនេះមានការវិភាគជាតារាងតួលេខ និងក្រាហ្វិក រួមជាមួយនឹងការអធិប្បាយខ្លីៗ ដែលអាចជាប្រភពទិន្នន័យព័ត៌មានសម្រាប់អ្នកប្រើប្រាស់គ្រប់រូបភាពដែលមានចំណាប់អារម្មណ៍ទៅលើទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។ ទិន្នន័យនៅក្នុងសៀវភៅនេះ ត្រូវបានផលិតឡើងដំបូងបំផុតដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយមន្ទីរផែនការខេត្ត ដោយជំហានទី១ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន៥ខេត្ត (ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ) ហើយជំហានទី២ បានចំនួន៤ខេត្ត ដែលស្ថិតនៅតំបន់ឆ្នេរសមុទ្រ (ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ) ចំណែកជំហានទី៣ បានចំនួន ៥ខេត្ត (ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ) ឯជំហានទី៤ បានចំនួន២ខេត្ត (ខេត្តកណ្តាល និងខេត្តតាកែវ) ចំណែកឯជំហានទី៥ បានចំនួន១ខេត្ត (ខេត្តស្វាយរៀង) និងជំហានទី៦ ឆ្នាំ ២០២១នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ក៏បានបន្តចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន ១ខេត្តទៀត គឺខេត្តព្រៃវែង។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណចំពោះក្រុមការងារនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ និងមន្ទីរផែនការខេត្តព្រៃវែង ដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរៀបចំ ចងក្រង បោះពុម្ពនូវរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដ៏មានសារៈសំខាន់ជាលើកទី៦ នេះឡើង៕៚

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហាន លីណា**

ភ្នំពេញ កម្ពុជា

ខែធ្នូ ឆ្នាំ២០២២

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. សេចក្តីផ្តើម

ស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងថ្មីមួយដែលវិទ្យាស្ថានជាតិស្ថិតិបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យស្ថិតិនៅថ្នាក់មូលដ្ឋាន និងធ្វើការវិភាគលើលទ្ធផលទាំងនោះស្របតាមការធ្វើវិមជ្ឈការ និងសហវិមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ។

ស្ថិតិដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋានដើម្បីយកមកវិភាគ ចងក្រង រួមមាន៖ ស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកអនុវត្តគម្រោងនេះដោយផ្ទាល់ ដែលស្របទៅតាមភារកិច្ចរបស់នាយកដ្ឋាន និងសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ស្នើឲ្យបង្កើតនាយកដ្ឋាននេះឡើងតាមអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤។

ប្រទេសកម្ពុជាបានបែងចែកជា៤តំបន់សំខាន់ៗគឺ៖ តំបន់ភ្នំ និងខ្ពង់រាប តំបន់វាលទំនាប តំបន់បឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រ។ យ៉ាងណាមិញ នៅឆ្នាំ២០២១នេះដែរ វាគឺជាជំហានទី៦ហើយដែលនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បាននិងកំពុងបន្តអនុវត្តគម្រោងរបស់ខ្លួន។

ព្រៃវែង គឺជាឈ្មោះនៃខេត្តមួយដែលត្រូវជ្រើសរើសយកមកអនុវត្តគម្រោងក្នុងចំណោម រាជធានីខេត្តទាំង២៥របស់ប្រទេសកម្ពុជា។ ខេត្តនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩០៧ ហើយរហូតមកដល់បច្ចុប្បន្នមាន ១៣ក្រុង/ស្រុក ១១៦ឃុំ/សង្កាត់ និង ១១៤៩ភូមិ។ ទីតាំងភូមិសាស្ត្រស្ថិតនៅភាគខាងកើតនៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ចាម និងត្បូងឃ្មុំ ខាងកើតជាប់ខេត្តស្វាយរៀង និងប្រទេសវៀតណាម ខាងត្បូងជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តកណ្តាល ដែលមានផ្ទៃដីសរុបប្រហែល ៤.៨៨៣ គម$^{២}$ ស្មើនឹង ២,៧០% នៃផ្ទៃដីសរុបប្រទេសកម្ពុជា (១៨១.០៣៥ គម$^{២}$)។ ខេត្តព្រៃវែងមានច្រកអន្តរជាតិសំខាន់ចំនួន ៣កន្លែង គឺ៖ ទី១ ច្រកអន្តរជាតិម៉ឺនជ័យ (ស្រុកកំចាយមារ) ទី២ ច្រកអន្តរជាតិបន្ទាយចក្រី (ស្រុកព្រះស្តេច) និងទី៣ គឺច្រកអន្តរជាតិកោះរការ (ស្រុកពាមជរ)។ ចំណែកឯកន្លែងកម្សាន្តវិញ ខេត្តនេះមានតំបន់ទេសចរណ៍ (តំបន់ទេសចរណ៍វប្បធម៌ តំបន់ទេសចរណ៍ធម្មជាតិ និងតំបន់ទេសចរណ៍កែច្នៃ) ជាច្រើនដែលអាចទាក់ទាញភ្ញៀវក្នុងស្រុកក៏ដូចជាមកពីបណ្តាខេត្តក្រុងផ្សេងៗក្នុងប្រទេសកម្ពុជា និងភ្ញៀវទេសចរណ៍បរទេសផងដែរ។

ខាងក្រោមនេះ គឺជាតំបន់ទេសចរណ៍ដែលទេសចរជាតិ និង អន្តរជាតិអាចមកទស្សនាកម្សាន្តបាន៖

**១. រមណីយដ្ឋាននគរភ្នំ៖** គឺជារមណីយដ្ឋានគំរូមួយដែលស្ថិតនៅក្នុងស្រុកបាភ្នំ និងមានអ្នកទេសចរជាច្រើនមកពីតំបន់ផ្សេងៗជួបជុំគ្នាដើម្បីប្រារព្ធធ្វើពិធីសាសនាតាមលទ្ធិព្រាហ្មណ៍មួយគឺ "បុណ្យឡើងអ្នកតាមេសរ" ដែលមានរយៈពេល៣ថ្ងៃ។ ប្រជាជនខ្មែរតែងតែនាំគ្នាប្រារព្ធធ្វើពិធីបុណ្យនេះឡើងជារៀងរាល់ឆ្នាំ ព្រោះវាជាទំនៀមទម្លាប់មានតាំងពីបុរាណកាល ដើម្បីរម្លឹកដល់គុណបុព្វបុរស សុំសេចក្ដីសុខ សុំទឹកភ្លៀង និងជាពិសេសដើម្បីសុំឱ្យអ្នកតាមេសរជួយការពារសុវត្ថិភាព និងសន្តិសុខជូនប្រជាជនគ្រប់រូបភាព។

**២. ប្រាសាទព្រះវិហារច័ន្ទ៖** ស្ថិតនៅក្នុងស្រុកបាភ្នំ។

**៣. ទំនប់ស្នេហ៍៖** ស្ថិតនៅក្នុងស្រុកបាភ្នំ ប៉ុន្តែទីនេះមិនទាន់មានការរៀបចំកែច្នៃឲ្យក្លាយទៅជារមណីយដ្ឋានគួរជាទីទាក់ចិត្តនៅឡើយទេ។

**៤. មជ្ឈមណ្ឌលភ្ញាស់កូនត្រីពូជភូមិបាទី៖** ស្ថិតនៅឃុំពាមរក៍ ស្រុកពាមរក៍។

**៥. បូជនីយដ្ឋានបារមីបារាយណ៍អណ្ដែត៖** ស្ថិតនៅភូមិបារាយណ៍ សង្កាត់បារាយណ៍ ក្រុងព្រៃវែង។

**៦. តំបន់ចុងប៉ម៖** ស្ថិតនៅភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង។

**៧. ប្រាសាទព្រៃដើមស្រុក៖** ស្ថិតនៅឃុំព្រៃទទឹង ស្រុកស៊ីធរកណ្ដាល។

**៨. ទូក ង** វែងជាងគេលើពិភពលោក។

បើគេធ្វើដំណើរតាមផ្លូវគោកពីរាជធានីភ្នំពេញ ទៅទីរួមខេត្តព្រៃវែង (ក្រុងព្រៃវែង) គេអាចធ្វើដំណើរតាមផ្លូវដូចខាងក្រោម៖

- **ផ្លូវជាតិលេខ១ និងលេខ១១៖** ចេញពីច្បារអំពៅ ទៅទិសខាងកើត ដោយឆ្លងកាត់ស្រុកកៀនស្វាយ ខេត្តកណ្ដាល រួចបត់ឆ្វេងឆ្លងស្ពានអ្នកលឿង ហើយបត់ចូលតាមផ្លូវជាតិលេខ១១ ឆ្លងកាត់ស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានចម្ងាយប្រមាណ ៩០គីឡូម៉ែត្រ។
- **ផ្លូវជាតិលេខ៦ លេខ៨ និងលេខ១១៖** ចេញពីស្ពានជ្រោយចង្វារ ទៅទិសខាងជើង ដោយឆ្លងកាត់មុខកំពូល ខេត្តកណ្ដាល រួចបត់ស្ដាំឆ្លងស្ពានព្រែកតាមាក់ ចូលផ្លូវជាតិលេខ៨ ឆ្លងកាត់ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល និងស្រុកពារាំង ខេត្តព្រៃវែង ហើយបត់ស្ដាំចូលផ្លូវជាតិលេខ១១ នោះនឹងបានទៅដល់ទីរួមខេត្តព្រៃវែងតែម្ដង គ្រាន់តែមានចម្ងាយឆ្ងាយជាងមុនបន្តិច។

## ១.១.១. និមិត្តសញ្ញាសម្គាល់




ការប្រើប្រាស់នូវនិមិត្តសញ្ញាសម្គាល់នេះ គឺយោងទៅតាមប្រកាសលេខ ៦៦៣៨ ប្រក. ចុះថ្ងៃពុធ ៧រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ស្តីពី ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តព្រៃវែង។

## ១.១.២. ផែនទីខេត្តព្រៃវែង



### ១.១.៣. ផែនទីខេត្តដែលបានអនុវត្តគម្រោង




## ១.២. គោលបំណង

គោលបំណងសំខាន់ៗ នៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺដើម្បីផ្តល់នូវទិន្នន័យដែលជាតម្រូវការចាំបាច់សម្រាប់បម្រើសេចក្តីត្រូវការៈ

១. សម្រាប់ធ្វើគោលនយោបាយអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ

២. សម្រាប់ប្រើប្រាស់ក្នុងវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការ

៣. សម្រាប់តម្រូវការអ្នកសិក្សាស្រាវជ្រាវ សាស្ត្រាចារ្យ សិស្ស និស្សិត បណ្តាអង្គការជាតិ-អន្តរជាតិ ស្ថាប័នរដ្ឋ និងវិស័យឯកជនជាច្រើនទៀត។

នៅក្នុងជំពូកបន្ទាប់ មានបង្ហាញយ៉ាងលម្អិតនូវទិន្នន័យជាច្រើនដែលទាក់ទងទៅនឹងព័ត៌មានប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងផ្នែកកសិកម្ម។ ក្រៅពីការបោះពុម្ពផ្សាយចេញនូវសៀវភៅ "របាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១" នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិក៏មានការផ្សព្វផ្សាយដោយបើកចំហនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ដែលមានអាសយដ្ឋាន https://www.nis.gov.kh ផងដែរ។

## ១.៣. វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺត្រូវបានធ្វើឡើងដោយការសម្ភាសទល់មុខ (Face to Face) និងប្រើប្រាស់ម៉ាស៊ីនថេប្លេត តាមរយៈកម្មវិធីឌីជីថល (Kobo Toolbox)។ កម្រងបញ្ជីសំណួរស្ថិតិថ្នាក់ក្រោមជាតិនេះ ត្រូវបានចុះសម្ភាសន៍គ្រប់ភូមិដែលមាននៅក្នុងខេត្តជាមួយមេភូមិទាំងអស់រយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី០៦ ដល់ ២០ ខែមីនា ឆ្នាំ២០២១ ដោយមន្ត្រីនៃមន្ទីរផែនការខេត្តព្រៃវែងក្រោយពីទទួលបានការបណ្តុះបណ្តាលយ៉ាងលម្អិត និងច្បាស់លាស់រួចមក។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកសម្របសម្រួលផ្នែកបច្ចេកទេស តាំងពីចាប់ផ្តើមដំណើរការ រហូតដល់ការប្រមូលទិន្នន័យត្រូវបានបញ្ចប់ដោយជោគជ័យ១០០ភាគរយ។ ចំណែកកាលបរិច្ឆេទយោងនៃការប្រមូលទិន្នន័យនេះ គឺយករយៈពេល១២ខែកន្លងមក ដោយគិតចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១។

## ១.៤. ការផលិតទិន្នន័យ

ការផលិតទិន្នន័យ គឺត្រូវបានធ្វើឡើងដោយការទាញយកទិន្នន័យពីកម្មវិធី Kobo Toolbox បំប្លែងទៅជា Microsoft Excel ដើម្បីបង្កើតជាតារាង សង់ជាក្រាហ្វិក និងវិភាគទិន្នន័យ មុននឹងឈានដល់ការបកស្រាយទិន្នន័យក្នុងកម្មវិធី Microsoft Word។ ដំណើការផលិត និងវិភាគទិន្នន័យមានរយៈពេល០៣ខែ គឺចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ បន្ទាប់ពីការចុះស្រង់ទិន្នន័យតាមមូលដ្ឋានរួចមក។

# ជំពូកទី២

# វិភាគទិន្នន័យ

## ២.១. ព័ត៌មានប្រជាសាស្ត្រ

### ២.១.១. ព័ត៌មានគ្រួសារ

**គ្រួសារ** គឺជាមនុស្សមួយក្រុមដែលរស់នៅរួមគ្នា និងបរិភោគអាហារចេញពីចង្ក្រានតែមួយ វៀរលែងតែអ្នកដែលមានការងារពិសេសមិនអាចទៅហូបចុកជាមួយបាន។

**មេគ្រួសារ** គឺជាមនុស្សដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងគ្រួសារ។ មេគ្រួសារអាចជាបុរស ឬស្ត្រី ដែលជាទូទៅគាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងគ្រួសារ និងធ្វើការសម្រេចចិត្តក្នុងនាមឱ្យគ្រួសារ។ មេគ្រសារ មិនចាំបាច់ត្រូវតែជាមនុស្សចាស់ទេ ប៉ុន្តែគាត់អាចជាស្ត្រី ក្មេងស្រី ឬក្មេងប្រុស នៃសមាជិកគ្រួសារ។

*តារាងទី១៖ ចំនួន និងភេទមេគ្រួសារនៅតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួន | | |
|---|---|---|---|
| | បុរសជាមេគ្រួសារ | ស្ត្រីជាមេគ្រួសារ | សរុបគ្រួសារ |
| កញ្ជៀច | ១៥.០៩១ | ៣.១២០ | ១៨.២១១ |
| កំចាយមារ | ២១.១៥៩ | ៥.២៩៦ | ២៦.៤៥៥ |
| កំពង់ត្របែក | ២៧.៣០៩ | ៥.៥២៣ | ៣២.៨៣២ |
| បាភ្នំ | ១៩.៧៦០ | ៤.៥៩១ | ២៤.៣៥១ |
| ពាមជរ | ១៤.១៨៦ | ១.៩១៩ | ១៦.១០៥ |
| ពាមរក៍ | ១២.៧៧៨ | ២.៥៩០ | ១៥.៣៦៨ |
| ពារាំង | ២៦.០២៤ | ៣.៧៤០ | ២៩.៧៦៤ |
| ពោធិ៍រៀង | ១០.៦៤៨ | ១.៥៥២ | ១២.២០០ |
| ព្រៃវែង | ៦.៨២១ | ១.៧២១ | ៨.៥៤២ |
| ព្រះស្ដេច | ២៨.៥២៦ | ៤.៧៧៣ | ៣៣.២៩៩ |
| មេសាង | ២៤.៥២៥ | ៥.២៥៨ | ២៩.៧៨៣ |
| ស៊ីធរកណ្ដាល | ១៤.៥៦២ | ៣.៦៤០ | ១៨.២០២ |
| ស្វាយអន្ទរ | ២៥.៨៤៦ | ៤.៦២៨ | ៣០.៤៧៤ |
| **សរុបរួម** | **២៤៧.២៣៥** | **៤៨.៣៥១** | **២៩៥.៥៨៦** |




*រូបភាពទី១៖ ភាគរយនៃចំនួនមេគ្រួសារ*

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

តារាង និងរូបភាពទី១ បានបង្ហាញពីចំនួន និងភេទមេគ្រួសារនៅតាមក្រុង/ស្រុកទាំង១៣ នៃខេត្តព្រៃវែង។ យើងឃើញថា នៅក្នុងខេត្តនេះមានគ្រួសារសរុបចំនួន ២៩៥.៥៨៦គ្រួសារ ដែលក្នុងនោះស្ត្រីជាមេគ្រួសារមាន ៤៨.៣៥១គ្រួសារ ស្មើនឹង ១៦% នៃចំនួនគ្រួសារសរុប។ បើពិនិត្យមើលនៅតាមក្រុង/ស្រុកវិញឃើញថា ស្រុកព្រះស្ដេច ជាស្រុកមួយដែលមានចំនួនគ្រួសាររស់នៅច្រើនជាងគេ (៣៣.២៩៩គ្រួសារ) បន្ទាប់មក គឺស្រុកកំពុងត្របែក (៣២.៨៣២គ្រួសារ) ស្រុកស្វាយអន្ទរឈរនៅលើលំដាប់ទីបី (៣០.៤៧៤គ្រួសារ) ហើយបន្តបន្ទាប់មកទៀត គឺស្រុកមេសាង ពារាំង កំចាយមារ បាភ្នំ (ស្រុកនីមួយៗមានប្រហែលជាង ២០.០០០គ្រួសារ) ស្រុកកញ្ជ្រៀច ស៊ីធរកណ្ដាល ពាមជរ ពាមរក៍ ពោធិ៍រៀង (ស្រុកនីមួយៗមានប្រហែលជាង ១០.០០០គ្រួសារ) និងចុងក្រោយគឺក្រុងព្រៃវែង ដែលមានចំនួនគ្រួសារតិចជាងគេបង្អស់ បើធៀបទៅនឹងចំនួនគ្រួសារនៅតាមស្រុកនីមួយៗ (មានត្រឹមតែ ៨.៥៤២ គ្រួសារប៉ុណ្ណោះ)។

*តារាងទី២៖ ចំនួនស្ត្រីជាមេគ្រួសារដែលមានក្មេងអាយុក្រោម៥ឆ្នាំនៅតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ស្ត្រីជាមេគ្រួសារដែលមានក្មេងអាយុក្រោម៥ឆ្នាំ | |
|---|---|---|
| | ចំនួន | ភាគរយ |
| កញ្ជ្រៀច | ៣១៥ | ១០ |
| កំចាយមារ | ៥០៦ | ១០ |
| កំពង់ត្របែក | ៧៨០ | ១៤ |
| បាភ្នំ | ៤៨៧ | ១១ |
| ពាមជរ | ២៥១ | ១៣ |
| ពាមរក៍ | ១៨៥ | ៧ |
| ពារាំង | ៤៨០ | ១៣ |
| ពោធិ៍រៀង | ១៩៣ | ១២ |
| ព្រៃវែង | ៤០៥ | ២៤ |
| ព្រះស្ដេច | ៥៤៣ | ១១ |
| មេសាង | ៧៣៦ | ១៤ |
| ស៊ីធរកណ្ដាល | ៨៨៨ | ២៤ |
| ស្វាយអន្ទរ | ៩០១ | ១៩ |
| **សរុប** | **៦.៦៧០** | **១៤** |

តារាងទី២ បានបង្ហាញថា ក្នុងចំណោមស្ត្រីជាមេគ្រួសារទាំង ៤៨.៣៥១គ្រួសារ គឺមាន ៦.៦៧០ គ្រួសារ ស្មើនឹង ១៤% មានក្មេងអាយុក្រោម៥ឆ្នាំ ស្នាក់នៅ និងកំពុងរស់នៅជាមួយ។ ក្នុងនោះក្រុងព្រៃវែង និងស្រុកស៊ីធរកណ្ដាលមានតួលេខខ្ពស់ជាងគេ គឺ ២៤% ខណៈដែលស្រុកពាមរក៍មានតិចជាងគេ មានត្រឹមតែ ៧% ប៉ុណ្ណោះបើធៀបទៅនឹងក្រុង/ស្រុកទាំងអស់ដែលមាននៅក្នុងខេត្តព្រៃវែង។

*រូបភាពទី២៖ ចំនួនគ្រួសារតាមជនជាតិ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

តាមរូបភាពនេះ (រូបភាពទី២) បានបង្ហាញថា គ្រួសារនៃជនជាតិ (ផ្អែកតាមមេគ្រួសារ) ស្ទើរតែទាំងអស់ដែលរស់នៅក្នុងខេត្តព្រៃវែង គឺជាគ្រួសារជនជាតិខ្មែរ ដែលមានរហូតដល់ ២៩៥.១២៤គ្រួសារ ស្មើនឹង ៩៩,១៧% ចំណែកឯគ្រួសារជនជាតិផ្សេងទៀតដូចជា វៀតណាម ឥស្លាម និងចិន មានត្រឹមតែ ២.៤៦២គ្រួសារ ស្មើនឹង ០,៨៣% នៃគ្រួសារតាមជនជាតិតែប៉ុណ្ណោះ។

### ២.១.២. ព័ត៌មានប្រជាជន

**ប្រជាជន** គឺសំដៅដល់មនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ជាតិសាសន៍ ដែលរស់នៅ ឬធ្វើការក្នុងប្រទេសណាមួយជាក់លាក់។

#### ក. ចំនួនប្រជាជន

*តារាងទី៣៖ ចំនួនប្រជាជននៅតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួនប្រជាជន | | |
|---|---|---|---|
| | ប្រុស | ស្រី | សរុប |
| កញ្ជ្រៀច | ៣៥.៦១៦ | ៣៨.៩០០ | ៧៤.៥១៦ |
| កំចាយមារ | ៤៩.០០៣ | ៥១.៤០២ | ១០០.៤០៥ |
| កំពង់ត្របែក | ៧១.១៤០ | ៧៤.៨៧៩ | ១៤៦.០១៩ |
| បាភ្នំ | ៤៨.០៦៦ | ៥១.៨២៥ | ៩៩.៨៩១ |
| ពាមជរ | ៣៦.៩៥២ | ៣៨.០៤៨ | ៧៥.០០០ |
| ពាមរក៍ | ៣៥.២២៦ | ៣៦.៦៥០ | ៧១.៨៧៦ |
| ពារាំង | ៦០.៦១២ | ៦៥.៤០៩ | ១២៦.០២១ |
| ពោធិ៍រៀង | ២៤.៣២៤ | ២៥.៧៩៣ | ៥០.១១៧ |
| ព្រៃវែង | ១៥.០៨៤ | ១៦.១៩៧ | ៣១.២៨១ |
| ព្រះស្ដេច | ៧០.៣១១ | ៧២.៩៦១ | ១៤៣.២៧២ |
| មេសាង | ៦២.០៩៤ | ៦៨.០៦១ | ១៣០.១៥៥ |
| ស៊ីធរកណ្ដាល | ៤០.៨៥៥ | ៤៣.៤២៣ | ៨៤.២៧៨ |
| ស្វាយអន្ទរ | ៥៩.៣១៦ | ៦៣.២១៦ | ១២២.៥៣២ |
| **សរុបរួម** | **៦០៨.៥៩៩** | **៦៤៦.៧៦៤** | **១.២៥៥.៣៦៣** |



ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១

តារាង និងរូបភាពទី៣ខាងលើនេះ បានបង្ហាញថា ចំនួនប្រជាជនសរុបក្នុងខេត្តព្រៃវែងមាន ១.២៥៥.៣៦៣នាក់ ដែលក្នុងនោះមាន ៦៤៦.៧៦៤នាក់ ស្មើនឹង ៤៨% ជាស្ត្រី (ប្រហាក់ប្រហែលនឹងប្រជាជនជាបុរស គឺតិចជាងគ្នាតែ ៤% ប៉ុណ្ណោះ)។ បើនិយាយពីចំនួនប្រជាជននៅតាមក្រុង/ស្រុកវិញ ស្រុកកំពង់ត្របែកមានចំនួនប្រជាជនច្រើនជាងគេគឺ ១៤៦.០១៩នាក់ ស្មើនឹង ១២% (ស្រី ៧៤.៨៧៩នាក់) បន្ទាប់មកគឺស្រុកព្រះស្ដេច ដែលមានប្រជាជនចំនួន ១៤៣.២៧២នាក់ ស្មើនឹង ១១% (ស្រី ៧២.៩៦១នាក់) បន្ទាប់មកទៀតស្រុកមេសាងមានប្រជាជនចំនួន ១៣០.១៥៥នាក់ ស្មើនឹង ១០% (ស្រី ៦៨.០៦១នាក់) ស្រុកពារាំងមាន ១២៦.០២១នាក់ ស្មើនឹង ១០% (ស្រី ៦៥.៤០៩នាក់) ស្រុកស្វាយអន្ទរមាន ១២២.៥៣២នាក់ ស្មើនឹង ១០% (ស្រី ៦៣.២១៦នាក់) ស្រុកកំចាយមារ ១០០.៤០៥នាក់ ស្មើនឹង ៨% (ស្រី ៥១.៤០២ នាក់) ស្រុកបាភ្នំមាន ៩៩.៨៩១នាក់ ស្មើនឹង ៨% (ស្រី ៥១.៨២៥នាក់) ស្រុកស៊ីធរកណ្ដាលមាន ៨៤.២៧៨នាក់ ស្មើនឹង ៧% (ស្រី ៤៣.៤២៣នាក់) ស្រុកពាមជរមាន ៧៥.០០០នាក់ ស្មើនឹង ៦% (ស្រី ៣៨.០៤៨នាក់) ស្រុកកញ្ជៀចមាន ៧៤.៥១៦នាក់ ស្មើនឹង ៦% (ស្រី ៣៨.៩០០នាក់) ស្រុកពាមរក៍មាន ៧១.៨៧៦នាក់ ស្មើនឹង ៦% (ស្រី ៣៦.៦៥០នាក់) ស្រុកពោធិ៍រៀងមាន ៥០.១១៧នាក់ ស្មើនឹង ៤% (ស្រី ២៥.៧៩៣នាក់) ចំណែកឯក្រុងព្រៃវែងមានប្រជាជន ៣១.២៨១នាក់ ស្មើនឹង ២% (ស្រី ១៦.១៩៧នាក់) ដែលជាតួលេខតិចជាងគេ បើធៀបទៅនឹងប្រជាជនសរុបទូទាំងខេត្ត។

## ខ. ស្ថានភាពអាពាហ៍ពិពាហ៍

*តារាងទី៤៖ ចំនួនស្ថានភាពអាពាហ៍ពិពាហ៍តាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ស្ថានភាពអាពាហ៍ពិពាហ៍ | | | | |
|---|---|---|---|---|---|
| | រៀបការ និង កំពុងរស់នៅជាមួយគ្នា | មេម៉ាយ ឬពោះម៉ាយ | រស់នៅជាមួយគ្នាដោយមិនបានរៀបការ | រស់នៅផ្សេងគ្នា | មិនដែលរៀបការ |
| កញ្ជ្រៀច | ១៤.៤៧៩ | ៣.៦៤៩ | ៤១ | ១៨ | ២៤ |
| កំចាយមារ | ២១.៤៦៤ | ៤.៨៥២ | ៤៣ | ៣១ | ៦៥ |
| កំពង់ត្របែក | ២៦.៨៩៨ | ៥.៦៦៩ | ១០១ | ៩១ | ៧៣ |
| បាភ្នំ | ១៩.៨១៩ | ៤.០៧៨ | ១៨៦ | ៨០ | ១៨៨ |
| ពាមជរ | ១៣.៩៣៧ | ២.០១៣ | ៤៨ | ៧ | ១០០ |
| ពាមរក៍ | ១៣.៣៤៤ | ១.៩៩៦ | ១៥ | ៩ | ៤ |
| ពារាំង | ២៥.៦៨២ | ៣.៨៥៥ | ៦៤ | ១០៣ | ៦០ |
| ពោធិ៍រៀង | ១០.០២៥ | ១.៩៩៧ | ៣២ | ១៩ | ១២៧ |
| ព្រៃវែង | ៦.៨០០ | ១.៦១១ | ២២ | ១៣ | ៩៦ |
| ព្រះស្ដេច | ២៨.១៩៩ | ៤.៦១០ | ៩៧ | ៥៩ | ៣៣៤ |
| មេសាង | ២៤.២៧៥ | ៥.២៤៦ | ៨១ | ៣៣ | ១៤៨ |
| ស៊ីធរកណ្ដាល | ១៤.៩៥៧ | ៣.១១៩ | ៤៥ | ១៦ | ៦៥ |
| ស្វាយអន្ទរ | ២៦.១៦១ | ៤.១៦៦ | ៥៥ | ៣០ | ៦២ |
| សរុប | ២៤៦.០៤០ | ៤៦.៨៦១ | ៨៣០ | ៥០៩ | ១.៣៤៦ |




*រូបភាពទី៤៖ ភាគរយនៃស្ថានភាពអាពាហ៍ពិពាហ៍*

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

តារាង និងរូបភាពទី៤ បានបង្ហាញពីស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារនៅតាមក្រុង/ស្រុកនៃខេត្តព្រៃវែង។ ខេត្តនេះមានគ្រួសារសរុបចំនួន ២៩៥.៥៨៦គ្រួសារ ដែលក្នុងនោះយើងឃើញថា គ្រួសារបានរៀបការ និងកំពុងរស់នៅជាមួយគ្នាមានចំនួន ២៤៦.០៤០គ្រួសារ (៨៣,២៤%) ខណៈដែលគ្រួសារមេម៉ាយ ឬពោះម៉ាយមាន ៤៦.៨៦១គ្រួសារ (១៥,៨៥%) បន្ទាប់មកគឺគ្រួសារមិនបានរៀបការ (នៅលីវ) មានចំនួន ១.៣៤៦គ្រួសារ (០,៤៦%) គ្រួសារដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការមាន ៨៣០គ្រួសារ (០,២៨%) ចំណែកឯគ្រួសាររស់នៅផ្សេងគ្នាមានចំនួនតិចតួចបំផុត គឺមានតែ ៥០៩គ្រួសារ (០,១៧%) ប៉ុណ្ណោះ។

## ២.១.៣. ការផ្លាស់ប្តូរទីលំនៅ

**ការផ្លាស់ប្តូរទីលំនៅ** គឺជាចលនាផ្លាស់ប្តូរទីកន្លែងរស់នៅរបស់មនុស្សពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ ជាទូទៅ គេចាត់ទុកចលនាបំលាស់លំនៅជាបាតុភូតសកល ពីព្រោះចលនានេះតែងតែកើតមានឡើងនៅគ្រប់ប្រទេសទាំងអស់ មិនថាប្រទេសអ្នកមាន ឬប្រទេសអ្នកក្រនោះទេ។ កត្តាចម្បងដែលនាំឱ្យមានការបញ្ហានេះ គឺដោយសារវិបត្តិសេដ្ឋកិច្ច តម្លៃទំនិញឡើងថ្លៃ ការប្តូរកន្លែងធ្វើការ ការស្វែងរកការងារធ្វើ អសន្តិសុខ ការវិលជួបជុំគ្រួសារ កូនកំព្រា និងការបាត់បង់ដីធ្លី ឬលំនៅឋាន។ នៅកម្ពុជាបច្ចុប្បន្ន គេចែកបំលាស់លំនៅជាបួនរូបភាព គឺបំលាស់លំនៅពីជនបទទៅទីក្រុង បំលាស់លំនៅពី

ជនបទទៅជនបទ បំលាស់លំនៅពីទីក្រុងទៅទីក្រុង និងបំលាស់លំនៅពីទីក្រុងទៅជនបទ។ មួយរយៈចុងក្រោយនេះ គេសង្កេតឃើញមានការផ្លាស់លំនៅពីជនបទទៅជនបទច្រើន ដោយសារកំណើននៃសេដ្ឋកិច្ចជាពិសេសគឺតម្លៃដីធ្លីឡើងថ្លៃ ដែលធ្វើឲ្យប្រជាជនធ្វើការលក់ដូរដីពីកន្លែងដែលដីមានតម្លៃថ្លៃ ទៅរស់នៅកន្លែងមួយទៀត។ រូបភាពបំលាស់លំនៅ ពីជនបទទៅទីក្រុង ជារូបភាពដែលបណ្តាលឲ្យមានបញ្ហានគរូនីយកម្ម និងបង្កឲ្យមានចំណោទលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ថែមទៀតផង។

### ក. គ្រួសារ និងប្រជាជនចំណូលស្រុក

**ចំណូលស្រុក** គឺជាការផ្លាស់ទីចូលមករស់នៅក្នុងភូមិចាប់ពី៦ខែឡើងទៅ។

*តារាងទី៥៖ ចំនួនគ្រួសារ និងប្រជាជនចំណូលស្រុកតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំណូលស្រុក | |
|---|---|---|
| | គ្រួសារ | ប្រជាជន |
| កញ្ជ្រៀច | ៨៥ | ២៦៩ |
| កំចាយមារ | ១៤១ | ៤០១ |
| កំពង់ត្របែក | ១៤ | ៤៨ |
| បាភ្នំ | ១៧១ | ៧២២ |
| ពាមជរ | ៣៩ | ២៥១ |
| ពាមរក៍ | ៣៦ | ១៨៦ |
| ពារាំង | ៣៤ | ៥១៣ |
| ពោធិ៍រៀង | ១៦ | ៥៧ |
| ព្រៃវែង | ៣២ | ៧៦ |
| ព្រះស្តេច | ១៣៤ | ៤៥៧ |
| មេសាង | ១០០ | ៤៧៣ |
| ស៊ីធរកណ្តាល | ៥៣ | ១៥៤ |
| ស្វាយអន្ទរ | ១២៣ | ៣៨៧ |
| **សរុប** | **៩៧៨** | **៣.៩៩៤** |

តារាងទី៥ បានបង្ហាញអំពីចលនាចំណូលស្រុកដែលមានទំនាក់ទំនងទៅនឹងកត្តាសេដ្ឋកិច្ច និងសង្គម។ អត្រាចំណូលស្រុកនៅទូទាំងខេត្តមានចំនួន ៩៧៨គ្រួសារ ដែលស្មើនឹង ៣.៩៩៤នាក់។ តារាងនេះក៏បានបង្ហាញផងដែរថា នៅក្នុងស្រុកបាភ្នំ មានគ្រួសារចំណូលស្រុកច្រើនជាងគេ គឺចំនួន១៧១គ្រួសារ (៧២២នាក់) បើប្រៀបធៀបទៅនឹងស្រុកផ្សេងៗទៀតក្នុងខេត្ត។ កំចាយមារ គឺជាស្រុកដែលស្ថិតនៅលំដាប់ទី២នៃគ្រួសារចំណូលស្រុកសរុប ដែលមានចំនួន ១៤១គ្រួសារ (៤០១នាក់)។ ដោយឡែកស្រុកកំពង់ត្របែក មានគ្រួសារចំណូលស្រុកតិចជាងគេ ចំនួន១៤គ្រួសារ (៤៨នាក់)។




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៥៖ បង្ហាញពីរបាយនៃប្រជាជនចំណូលស្រុកតាមភេទក្នុងខេត្តព្រៃវែង។ ក្នុងនោះយើងឃើញថា ភេទប្រុសមានចំនួនលើសភេទស្រី ២% (ប្រុស ៥១%, ស្រី ៤៩%)។

## ខ. គ្រួសារ និងប្រជាជនចំណាកស្រុក

**ចំណាកស្រុក** គឺជាការផ្លាស់ទីចេញពីភូមិចាប់ពីរយៈពេល ៦ខែឡើងទៅ។

*តារាងទី៦៖ ចំនួនគ្រួសារ និងប្រជាជនចំណាកស្រុកតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំណាកស្រុក | |
|---|---|---|
| | គ្រួសារ | ប្រជាជន |
| កញ្ជៀច | ២៧៦ | ១.៤៣៤ |
| កំចាយមារ | ១.១៣៦ | ៤.២៨៣ |
| កំពង់ត្របែក | ៩៤២ | ២៣.៥២៩ |
| បាភ្នំ | ១.៤៦៩ | ៥.០៦៨ |
| ពាមជរ | ៥៧ | ៣១១ |
| ពាមរក៍ | ៧៦ | ១.២៣៦ |
| ពារាំង | ៧៦ | ២.៦១៧ |
| ពោធិ៍រៀង | ៣៧៣ | ១.៤៩៩ |
| ព្រៃវែង | ៣៦៩ | ១.០១២ |
| ព្រះស្ដេច | ១.៧២៤ | ៦.៦៧៧ |
| មេសាង | ១.៤៣៧ | ១១.០១៦ |
| ស៊ីធរកណ្ដាល | ៥៩៨ | ១៦.២០៦ |
| ស្វាយអន្ទរ | ៥៣៦ | ៣.៣២៧ |
| **សរុប** | **៩.០៦៩** | **៧៨.២១៥** |

តារាងទី៦ បានបង្ហាញអំពីចលនាចំណាកស្រុកដែលមានទំនាក់ទំនងទៅនិងកត្តាសេដ្ឋកិច្ច និងសង្គម។ អត្រាចំណាកស្រុកនៅទូទាំងខេត្តមានចំនួន ៩.០៦៩គ្រួសារ ដែលស្មើនឹង ៧៨.២១៥នាក់។ តារាងនេះក៏បានបង្ហាញផងដែរថា នៅក្នុងស្រុកព្រះស្ដេចមានគ្រួសារចំណាកស្រុកច្រើនជាងគេ គឺចំនួន ១.៧២៤គ្រួសារ (៦.៦៧៧នាក់) បើប្រៀបធៀបទៅនឹងស្រុកផ្សេងៗទៀតក្នុងខេត្ត។ បន្ទាប់មកគឺស្រុកបាភ្នំ មាន ១.៤៦៩គ្រួសារ (៥.០៦៨នាក់) ដោយឡែកស្រុកពាមជរ មានគ្រួសារចំណូលស្រុកតិចជាងគេ ចំនួន ៥៧គ្រួសារ (៣១១នាក់)។




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៦ បង្ហាញពីរបាយនៃប្រជាជនចំណាកស្រុកតាមភេទក្នុងខេត្តព្រៃវែង។ ក្នុងនោះយើងឃើញថា ភេទប្រុសមានចំនួនតិចជាងភេទស្រី ២% (ប្រុស ៤៩%, ស្រី ៥១%)។

## ២.១.៤. លំនៅឋាន

គោលបំណងសំខាន់នៅក្នុងផ្នែកនេះ គឺដើម្បីបង្ហាញនូវទិន្នន័យស្ថិតិអំពីលំនៅឋានរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តព្រៃវែងទាំងអស់។ នៅឆ្នាំ២០២១ ខេត្តនេះមានគ្រួសារសរុបចំនួន ២៩៥.៥៨៦គ្រួសារ នោះចំនួនខ្នងផ្ទះអាចស្មើ ឬតិចជាងនេះ ដោយសារតែមានគ្រួសារមួយចំនួនរៀបការរួច ពុំទាន់មានលទ្ធភាពសាងសង់ផ្ទះសម្រាប់ស្នាក់នៅផ្ទាល់ខ្លួន ទើបទៅស្នាក់អាស្រ័យជាមួយផ្ទះឪពុកម្តាយ ឬបងប្អូនជាដើម។ សម្ភារៈប្រើប្រាស់សម្រាប់ធ្វើជាដំបូលផ្ទះ វាមានសារៈសំខាន់ណាស់ចំពោះការកំណត់នូវចរិតលក្ខណៈនៃគុណភាពរបស់លំនៅឋាន ដែលរួមមានដូចជា បេតុង ក្បឿង ហ្វីប្រូស៊ីម៉ងត៍ ស័ង្កសី ស្លឹក និងវត្ថុផ្សេងៗទៀត។

## ក. ប្រភេទដំបូលផ្ទះ

*តារាងទី៧៖ ចំនួនខ្នងផ្ទះតាមប្រភេទដំបូល*

| ប្រភេទដំបូល | ចំនួន | ភាគរយ |
|---|---|---|
| បេតុង | ៥.៦០៦ | ២,២ |
| ក្បឿង | ១៣៣.២១១ | ៥១,៨ |
| ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ | ១១៤.៨៥៧ | ៤៤,៧ |
| ស្លឹក | ២.៦២៤ | ១,០ |
| ផ្សេងៗ | ៦៨៥ | ០,៣ |
| សរុប | ២៥៦.៩៨៣ | ១០០ |

តារាងទី៧ បានបង្ហាញពីចំនួនខ្នងផ្ទះរបស់ប្រជាពលរដ្ឋទៅតាមប្រភេទដំបូល។ យើងឃើញថា នៅក្នុងខេត្តព្រៃវែងមានចំនួនខ្នងផ្ទះសរុប ២៥៦.៩៨៣ខ្នង ក្នុងនោះផ្ទះដំបូលប្រក់ក្បឿងមានចំនួនច្រើនជាងគេ គឺ ១៣៣.២១១ខ្នង (៥១,៨%) បន្ទាប់មក ផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ ដែលមានចំនួន ១១៤.៨៥៧ខ្នង (៤៤,៧%) បន្ទាប់មកទៀត គឺផ្ទះដំបូលបេតុង ៥.៦០៦ខ្នង (២,២%) ហើយផ្ទះដែលមានដំបូលប្រក់ស្លឹក ២.៦២៤ខ្នង (១%) ដោយឡែកផ្ទះដែលមានដំបូលប្រក់ពីសម្ភារៈផ្សេងៗទៀតក្រៅពីនេះមានចំនួន ៦៨៥ខ្នង (០,៣%) ដែលមានចំនួនទាបជាងគេបំផុត។

## ខ. ការប្រើប្រាស់បណ្តាញអគ្គិសនី

អគ្គិសនី គឺសំដៅលើប្រភពថាមពលដែលនាំឱ្យមានភ្លើងសម្រាប់ប្រើប្រាស់។ បណ្តាញ គឺជាការភ្ជាប់ពីទីតាំងមេ ដោយតជាសេរី ឬជាខ្សែ ដើម្បីចែកចាយបន្តទៅអ្នកប្រើប្រាស់ជាច្រើន។ បណ្តាញអគ្គិសនី វាអាចជាកម្មសិទ្ធិរបស់រដ្ឋ ឬជារបស់ឯកជន។




*រូបភាពទី៧៖ ភាគរយនៃខ្នងផ្ទះដែលមានអគ្គិសនីប្រើប្រាស់*

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៧ គឺជាភាគរយនៃខ្នងផ្ទះដែលមានបណ្តាញអគ្គិសនីប្រើប្រាស់។ តាមរូបភាពនេះបានបញ្ជាក់ថា បណ្តាញភ្លើងអគ្គិសនីបានលាតសណ្ឋឹង និងគ្របដណ្តប់ (៩៣%) ស្ទើរតែពាសពេញផ្ទៃខេត្តទាំងមូល។ ចំពោះខ្នងផ្ទះដំបូលក្បឿង ១៣៣.២១១ខ្នង គឺមាន៩៧% ដែលកំពុងប្រើប្រាស់ភ្លើងអគ្គិសនី បន្ទាប់មកគឺផ្ទះដំបូលបេតុងទាំង ៥.៦០៦ខ្នង គឺមាន៩៦% ផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ងត៍ចំនួន ១១៤.៨៥៧ខ្នង មាន៨៩% ហើយសូម្បីតែផ្ទះដំបូលប្រក់ស្លឹក/សម្ភារៈផ្សេងៗទៀតទាំង ៣៣.០៩ខ្នង ក៏មានភ្លើងអគ្គិសនីប្រើប្រាស់ ៧៤% ដែរ។

## គ. ការប្រើប្រាស់ទូរទស្សន៍

ទូរទស្សន៍ គឺជាឧបករណ៍កម្សាន្តអារម្មណ៍ ផ្តល់ចំណេះដឹង និងជាប្រព័ន្ធផ្សព្វផ្សាយដ៏សំខាន់មួយក្នុងការបញ្ជូនព័ត៌មានគ្រប់បែបយ៉ាងទៅកាន់អ្នកទស្សនា។ អាគុយ ម៉ាស៊ីនភ្លើង សឡា និងថាមពលមួយចំនួនទៀតក៏ត្រូវបានប្រើប្រាស់ផងដែរ ក្រៅពីបណ្តាញអគ្គិសនី។ នៅពេលប្រជាពលរដ្ឋមានប្រភពថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ពួកគាត់ភាគច្រើនអាចមានលទ្ធភាពក្នុងការប្រើប្រាស់ទូរទស្សន៍ដើម្បីបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួន ក្រុមគ្រួសារ និងញាតិមិត្តជិតខាង។

*រូបភាពទី៨៖ ភាគរយនៃខ្នងផ្ទះដែលមានទូរទស្សន៍ប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៨ សបញ្ជាក់ឱ្យឃើញថា នៅពេលដែលបណ្តាញភ្លើងអគ្គិសនីបានលាតសណ្ធឹង និងគ្របដណ្តប់ស្ទើរតែពាសពេញផ្ទៃខេត្តទាំងមូលហើយនោះ អត្រានៃអ្នកប្រើប្រាស់ទូរទស្សន៍ក៏មានកំណើនច្រើនផងដែរ។ ជាក់ស្តែង ក្នុងរូបភាពនេះយើងឃើញថា ៨៩% នៃចំនួនខ្នងផ្ទះសរុប គឺមានទូរទស្សន៍ប្រើប្រាស់។ ទន្ទឹមនោះ យើងក៏ឃើញផងដែរនូវចំនួនភាគរយ ធៀបទៅនឹងប្រភេទដំបូលផ្ទះនីមួយៗ ក្នុងនោះប្រជាពលរដ្ឋដែលមានផ្ទះដំបូលបេតុង៩៨% ផ្ទះដំបូលក្បឿង៩៣% បន្ទាប់មកគឺផ្ទះដំបូលស័ង្កសី/ហ្វីប្រូស៊ីម៉ងត៍មាន៨៥% និងផ្ទះដំបូលប្រក់ស្លឹក/សម្ភារៈផ្សេងៗទៀតមានចំនួន៦២% កំពុងប្រើប្រាស់ទូរទស្សន៍នៅតាមគេហដ្ឋានរបស់ខ្លួនផងដែរ។

## ឃ. ការប្រើប្រាស់កុំព្យូទ័រ

កុំព្យូទ័រ គឺជាឧបករណ៍មួយសម្រាប់ជំនួយ និងពន្លឿនការងារក្នុងសម័យទំនើប។

*រូបភាពទី៩៖ ភាគរយនៃខ្នងផ្ទះដែលមានកុំព្យូទ័រប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៩ បានបង្ហាញឱ្យឃើញថា នៅក្នុងខេត្តព្រៃវែងមិនសូវមានអ្នកចាប់អារម្មណ៍ ចេះ និងមានកុំព្យូទ័រប្រើប្រាស់ទេ។ ពិតណាស់ នៅក្នុងខ្នងផ្ទះទាំង ២៥៦.៩៨៣ខ្នង គឺមានតែ ០,៩% ប្រហែលជាស្មើ ជាង ២.៣០០ខ្នងផ្ទះតែប៉ុណ្ណោះដែលមានកុំព្យូទ័រប្រើប្រាស់។

## ង. ការប្រើប្រាស់អ៊ីនធឺណែត

អ៊ីនធឺណែត គឺជាប្រព័ន្ធទូរគមនាគមន៍សម្រាប់ប្រើប្រាស់ជាមួយកុំព្យូទ័រ ថេប្លេត ទូរសព្ទដៃ និងរបស់របរប្រើប្រាស់មួយចំនួនទៀត។ នៅក្នុងផ្នែកការប្រើប្រាស់អ៊ីនធឺណែតនៃរបាយការណ៍នេះ គឺគ្រាន់តែចង់សំដៅដល់ភូមិសាស្ត្រ និងទីតាំងខ្នងផ្ទះដែលអាចភ្ជាប់ ឬប្រើប្រាស់អ៊ីនធឺណែតបានតែប៉ុណ្ណោះ។

*រូបភាពទី១០៖ ភាគរយនៃខ្នងផ្ទះដែលមានអ៊ីនធឺណែតប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី១០ បានបង្ហាញពីភាគរយនៃខ្នងផ្ទះដែលមានអ៊ីនធឺណែតប្រើប្រាស់។ យើងឃើញថា បណ្តាគ្រប់ទីតាំងខ្នងផ្ទះទាំងអស់ ខ្នងផ្ទះដំបូលបេតុង៩៩% ផ្ទះដំបូលក្បឿង៩៨% ផ្ទះដំបូលស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍មាន៩៥% និងខ្នងផ្ទះដំបូលប្រក់ស្លឹក/សម្ភារៈផ្សេងៗទៀតមានចំនួន៨៨% ដែលអាចមានលទ្ធភាពភ្ជាប់ និងកំពុងប្រើប្រាស់។

## ច. ការប្រើប្រាស់ទូរសព្ទដៃ

សម័យបច្ចុប្បន្ននេះ ការប្រើប្រាស់សំបុត្រដើម្បីទាក់ទងគ្នាលែងសូវមានវត្តមានហើយ។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្រព័ន្ធបច្ចេកវិទ្យាកាន់តែទំនើបទៅៗ ទូរសព្ទដៃក៏បានក្លាយជាឧបករណ៍ដ៏ពិសេសមួយសម្រាប់ទំនាក់ទំនងគ្នា។ ទោះជានៅទីណា ឬកន្លែងណាក៏ដោយ ទូរសព្ទអាចមានលទ្ធភាពភ្ជាប់ដើម្បីជជែកគ្នា ទាំងរូបភាពភាព និងសំឡេង។

*រូបភាពទី១១៖ ភាគរយនៃខ្នងផ្ទះដែលមានទូរសព្ទដៃប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

ជាក់ស្តែង ដូចជានៅក្នុងរូបភាពទី១១នេះអ៊ីចឹង យើងឃើញថាមានខ្នងផ្ទះតែ ២%ប៉ុណ្ណោះ ដែលគ្មានលទ្ធភាពក្នុងការប្រើប្រាស់ទូរសព្ទដៃ។ ការរារាំងនេះ ប្រហែលជាដោយសារកត្តាសេដ្ឋកិច្ច ចំណេះដឹង ភូមិសាស្ត្រ និងបរិបទជុំវិញ។

## ២.១.៥. បរិក្ខារកសិកម្ម ដឹកជញ្ជូន និងប្រើប្រាស់

### ក. បរិក្ខារកសិកម្ម និងនេសាទ

*តារាងទី៨៖ ចំនួនគ្រួសារដែលមានបរិក្ខារកសិកម្ម និងនេសាទ*

| ប្រភេទ | ចំនួន | |
|---|---|---|
| | គ្រួសារ | បរិក្ខារ |
| ឧបករណ៍កសិកម្ម និងម៉ាស៊ីនភ្ជួររាស់ | ៥១.៥០៨ | ៥៤.០២០ |
| ម៉ាស៊ីនប្រមូលផល | ១.៦៥៨ | ១.៨៣៩ |
| រទេះគោ និងរទេះសេះ | ២៣៦ | ២៤១ |
| ទូកនេសាទ | ៤.២៦៩ | ៤.៤២៦ |
| **សរុប** | **៥៧.៦៧១** | **៦០.៥២៦** |




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

តារាងទី៨ និងរូបភាពទី១២ បានបង្ហាញពីចំនួនបរិក្ខារកសិកម្ម និងនេសាទដែលបានកាន់កាប់តាមគ្រួសារ ក្នុងនោះយើងឃើញថា ឧបករណ៍កសិកម្ម និងម៉ាស៊ីនភ្ជួររាស់មានចំនួន ៥៤.០២០គ្រឿង ស្មើនឹង៨៩,៣% (កាន់កាប់ដោយ ៥១.៥០៨គ្រួសារ) ម៉ាស៊ីនប្រមូលផលមាន ១.៨៣៩គ្រឿង ស្មើ៣% (កាន់កាប់ដោយ១.៦៥៨គ្រួសារ) ទូកនេសាទមាន ៤.៤២៦គ្រឿង ស្មើ៧,៣% (កាន់កាប់ដោយ

៤.២៦៩គ្រួសារ) ចំណែករទេះគោ និងរទេះសេះមិនសូវមានអ្នកប្រើប្រាស់ទេ បើធៀបទៅនឹងបរិក្ខារកសិកម្ម និងនេសាទដែលមានទាំងអស់ វាមានត្រឹមតែ ០,៤% ប៉ុណ្ណោះ។

## ខ. បរិក្ខារដឹកជញ្ជូន

*តារាងទី៩៖ ចំនួនគ្រួសារដែលមានបរិក្ខារសម្រាប់ដឹកជញ្ជូន*

| ប្រភេទ | ចំនួន | |
|---|---|---|
| | គ្រួសារ | បរិក្ខារ |
| រថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអី) | ១.២៦៩ | ១.៣២០ |
| រថយន្តដឹកទំនិញ | ៣.៦៥៥ | ៣.៩៥៧ |
| រថយន្តក្រុង | ១០០ | ១១២ |
| រទេះអូសដោយដៃ | ២.៦៣៩ | ២.៦៦៧ |
| ម៉ូតូកង់បី | ៤.២៧៧ | ៤.៣៤៤ |
| ទូកដឹកអ្នកដំណើរ | ២៩៧ | ៣០៧ |
| **សរុប** | **១២.២៣៧** | **១២.៧០៧** |

*រូបភាពទី១៣៖ ភាគរយបរិក្ខារសម្រាប់ដឹកជញ្ជូន*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

តារាងទី៩ និងរូបភាពទី១៣ បានបង្ហាញពីចំនួនបរិក្ខារសម្រាប់ដឹកជញ្ជូនដែលបានកាន់កាប់តាមគ្រួសារ ក្នុងនោះយើងឃើញថា ម៉ូតូកង់បីមានចំនួន ៤.៣៨៤គ្រឿង ស្មើនឹង៣៤,២% គឺជាតួលេខមានច្រើនជាងគេ (កាន់កាប់ដោយ៤.២៧៧គ្រួសា) បន្ទាប់គឺរថយន្តដឹកទំនិញ ដែលមាន ៣.៩៥៧ គ្រឿង ស្មើ៣១,១% (កាន់កាប់ដោយ៣.៦៥៥គ្រួសារ) បន្ទាប់ទៀតគឺរទេះអូសដោយដៃ មានចំនួន ២.៦៦៧គ្រឿង ស្មើ២១% (កាន់កាប់ដោយ២.៦៣៩គ្រួសារ) ហើយរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង ១២កៅអី) មាន១.៣២០គ្រឿង ស្មើ១០,៤% (កាន់កាប់ដោយ១.២៦៩គ្រួសារ) ទូកដឹកអ្នកដំណើរមាន ៣០៧គ្រឿង ស្មើ២,៤% (កាន់កាប់ដោយ២៩៧គ្រួសារ) និងចុងក្រោយ គឺរថយន្តក្រុងមាន១១២គ្រឿង ស្មើ០,៩% (កាន់កាប់ដោយ១០០គ្រួសារ) ដែលជាចំនួនតិចជាងគេ បើធៀបទៅនឹងបរិក្ខារសម្រាប់ដឹកជញ្ជូនសរុបដែលមាននៅក្នុងខេត្តនេះ។

### គ. បរិក្ខារប្រើប្រាស់ផ្ទាល់ខ្លួន

*តារាងទី១០៖ ចំនួនគ្រួសារដែលមានបរិក្ខារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន*

| ប្រភេទ | ចំនួន | |
|---|---|---|
| | គ្រួសារ | បរិក្ខារ |
| រថយន្តលក្ខណៈគ្រួសារ | ១១.៦១២ | ១១.៨១៨ |
| ម៉ូតូ | ២១៤.៧៥៣ | ២៣៤.១៦១ |
| ទូក | ៥.២៤០ | ៥.៣៥៩ |
| ផ្សេងៗ | ៦.៣៥៨ | ៦.៨៥៩ |
| **សរុប** | **២៣៧.៩៦៣** | **២៥៨.១៩៧** |




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

ផ្អែកតាមតារាងទី១០ និងរូបភាពទី១៤ យើងឃើញថា ម៉ូតូមានចំនួនច្រើនលើសលប់ បើធៀបទៅនឹងបរិក្ខារប្រើប្រាស់ផ្សេងទៀត។ វាមានរហូតដល់ ៩០,៧% (២៣៤.១៦១គ្រឿង)។ ចំណែកឯរថយន្តលក្ខណៈគ្រួសារមាន៤,៦% (១១.៨១៨គ្រឿង) ទូកមាន ២,១% (៥.៣៥៩គ្រឿង) និងចុងក្រោយគឺបរិក្ខារប្រើប្រាស់ផ្ទាល់ខ្លួនផ្សេងៗទៀត វាមាន ២,៦% ស្មើនឹង ៦.៨៥៩គ្រឿង។

## ២.២. អត្រាកំណើត និងមរណភាព

### ២.២.១. អត្រាកំណើត

*តារាងទី១១៖ ចំនួន និងកន្លែងកើតរបស់ទារកក្នុង១២ខែចុងក្រោយ*

| កន្លែងកើត | ចំនួនទារក | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| មន្ទីរពេទ្យរដ្ឋ | ៥.៩០៥ | ៦.៥០៥ | ១២.៤១០ | ៨៧,៥ |
| មន្ទីរពេទ្យឯកជន | ៨៩៨ | ៨៧២ | ១.៧៧០ | ១២,៥ |
| ផ្ទះឆ្មបបុរាណ | ១ | ២ | ៣ | ០,០ |
| **សរុបរួម** | **៦.៨០៤** | **៧.៣៧៩** | **១៤.១៨៣** | **១០០** |

តារាងទី១១ បានបង្ហាញនូវអត្រាកំណើតរបស់ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកហើយបែងចែកចំនួនទារកទៅតាមទីកន្លែងដែលបានសម្រាល។ រូបភាពនេះបានកំណត់បង្ហាញឱ្យឃើញថា អត្រាកំណើតភាគច្រើនគឺនៅមន្ទីរពេទ្យរដ្ឋ (មន្ទីរពេទ្យ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព ... ) មានចំនួន ១២.៤១០នាក់ (ស្រី ៦.៥០៥នាក់) ដែលស្មើនឹង ៨៧,៥% ចំណែកមន្ទីរពេទ្យឯកជន (មន្ទីរពេទ្យ មន្ទីរសម្រាកព្យាបាល គ្លីនិក សម្ភព ... ) មានចំនួន ១.៧៧០នាក់ (ស្រី ៨៧២នាក់) ស្មើនឹង ១២,៥%។ ថ្វីដ្បិតតែបច្ចេកទេសរីកចម្រើនក៏ពិតមែន ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនតូចគ្មានលទ្ធភាពទៅរកសេវានោះទេ។ ជាក់ស្តែងតារាងខាងលើ ក៏បានបង្ហាញផងដែរនូវចំនួនទារកដែលបានកើតនៅផ្ទះឆ្មបបុរាណ (ឆ្មបបុរាណជាអ្នកបង្កើត) គឺមានចំនួន ៣នាក់ (ស្រី ២នាក់) នៃកន្លែងទារកកើតទាំងអស់។




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

បើនិយាយពីកំណើតរបស់ទារកដោយបែងចែកតាមភេទវិញឃើញថា (រូបភាពទី១៥) ភាគរយនៃភេទទាំងពីរមិនសូវជាខុសគ្នាប៉ុន្មានឡើយ ដោយទារកភេទប្រុសមាន ៤៨% និងទារកភេទស្រីមាន ៥២%។

## ២.២.២. មរណភាព

ផ្នែកនេះ នឹងមានបង្ហាញនូវទិន្នន័យមួយចំនួនទាក់ទងទៅនឹងមូលហេតុចម្បងនៃការស្លាប់ដូចជា ស្លាប់ដោយជំងឺ គ្រោះថ្នាក់ចរាចរណ៍ លង់ទឹក ពស់ចឹក ឃាតកម្ម និងស្លាប់ដោយកត្តាផ្សេងៗទៀត។ ទន្ទឹមនោះ ទិន្នន័យនៃការស្លាប់តាមក្រុមអាយុ និងភេទ ក៏ត្រូវបានបង្ហាញផងដែរ។

### ក. មូលហេតុនៃការស្លាប់

*តារាងទី១២៖ ចំនួន និងមូលហេតុនៃការស្លាប់ក្នុង១២ខែចុងក្រោយ*

| មូលហេតុស្លាប់ | ចំនួន | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| ជំងឺ | ៣.០៧៧ | ៣.១៩៦ | ៦.២៧៣ | ៨៧,២១ |
| គ្រោះថ្នាក់ចរាចរណ៍ | ២៤៥ | ៧៥ | ៣២០ | ៤,៤៥ |
| លង់ទឹក | ៧៦ | ២៥ | ១០១ | ១,៤០ |
| ឃាតកម្ម | ៤២ | ៣ | ៤៥ | ០,៦៣ |
| ពស់ចឹក | ២ | ០ | ២ | ០,០៣ |
| ផ្សេងៗ | ២១៧ | ២៣៥ | ៤៥២ | ៦,២៨ |
| **សរុបរួម** | **៣.៦៥៩** | **៣.៥៣៤** | **៧.១៩៣** | **១០០** |

តារាងទី១២ បានបង្ហាញនូវមូលហេតុនៃអត្រាមរណភាពក្នុងរយៈពេល១២ខែមុនថ្ងៃចុះប្រមូលទិន្នន័យ។ នៅក្នុងចំណោមអ្នកស្លាប់ទាំងអស់ក្នុងខេត្ត (៧.១៩៣នាក់) អ្នកដែលស្លាប់ដោយសារជំងឺគឺមានចំនួនច្រើនជាងគេដែលមានរហូតដល់ទៅ ៦.២៧៣នាក់ (៨៧,២១%) បន្ទាប់មកគឺអ្នកស្លាប់ដោយសារមូលហេតុផ្សេងៗទៀតមានចំនួន ៤៥២នាក់ (៦,២៨%) បន្ទាប់មកទៀត គឺអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ក៏មានចំនួនគួរឱ្យកត់សម្គាល់ផងដែរ ដែលមានចំនួន ៣២០នាក់ (៤,៤៥%) ឯអ្នកស្លាប់ដោយលង់ទឹកមានចំនួន ១០១នាក់ (១,៤០%) ហើយអ្នកស្លាប់ដោយឃាតកម្មមានចំនួន ៤៥នាក់ (០,៦៣%) ចំណែកឯអ្នកស្លាប់ដោយសារពស់ចឹកមានចំនួនតិចជាងគេ គឺ ២នាក់ ដែលស្មើនឹង (០,០៣%) បើធៀបទៅនឹងមូលហេតុស្លាប់ផ្សេងៗទៀត។

## ខ. អាយុនៃអ្នកស្លាប់



*រូបភាពទី១៦៖ ចំនួនអ្នកស្លាប់តាមក្រុមអាយុ*

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី១៦ គឺជាចំនួននៃអត្រាមរណភាពនៅទូទាំងខេត្ត ដោយបែងចែកទៅតាមក្រុមអាយុ។ រូបភាពនេះបានបង្ហាញផងដែរថា នៅពេលមនុស្សវ័យកាន់តែច្រើន (៦៥ឆ្នាំឡើង) អត្រានៃការស្លាប់ក៏កាន់តែខ្ពស់ដែរ។ នៅក្នុងវ័យនេះយើងឃើញថា អ្នកស្លាប់ភាគច្រើនគឺជាមនុស្សស្រី ដែលមានចំនួន ១.៨៦៥នាក់ ខណៈដែលមនុស្សប្រុសស្លាប់ ១.៧០៦នាក់ ផ្ទុយពីមនុស្សវ័យកុមារ និងវ័យកណ្តាល ដែលមានមនុស្សប្រុសស្លាប់ច្រើនជាងមនុស្សស្រី។




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី១៧ គឺជាភាគរយនៃអ្នកស្លាប់ដោយបែងចែកតាមក្រុមអាយុ។ តាមរូបនេះបង្ហាញថា មនុស្សដែលស្ថិតនៅក្នុងក្រុមអាយុ ចាប់ពី៦៥ឆ្នាំឡើង មានអត្រាស្លាប់ច្រើនជាងគេ ៤៩,៥% បន្ទាប់មក គឺក្រុមអាយុ ១៨-៦៤ឆ្នាំ មាន ៤១,៧% បន្ទាប់មកទៀតគឺក្រុមអាយុ ៥-១៧ឆ្នាំ មាន ៦% ចំណែកឯក្រុម អាយុក្រោម៥ឆ្នាំមាន ២,៨% ដែលជាចំនួនតិចជាងគេបើធៀបទៅនឹងភាគរយនៃអ្នកស្លាប់ក្នុងក្រុមអាយុ ទាំងបួន។

## ២.៣. ពិការភាព និងបុគ្គលគ្មានអ្នកថែទាំ

ជនមានពិការភាព ត្រូវបានឲ្យនិយមន័យថា គឺជាឧបសគ្គ ឬជាកង្វះខាតផ្នែកសមត្ថភាពណាមួយ ក្នុងការអនុវត្តសកម្មភាព ឬនៅក្នុងកម្រិតមួយដែលមនុស្សធម្មតាអាចធ្វើបាន។

*តារាងទី១៣៖ ចំនួនបុគ្គលមានពិការភាព និងមនុស្សគ្មានអ្នកថែទាំ*

| បរិយាយ | ចំនួន | | |
|---|---|---|---|
| | ប្រុស | ស្រី | សរុប |
| ពិការភាព (ក្រោម១៨ឆ្នាំ) | ១.២៩៤ | ១.០៨១ | ២.៣៧៥ |
| ពិការភាព (អាចរកប្រាក់ចំណូលបាន) | ៦៩០ | ៣៦៨ | ១.០៥៨ |
| ពិការភាព (មិនអាចរកប្រាក់ចំណូលបាន) | ១.៤៣២ | ១.៣៩៦ | ២.៨២៨ |
| ពិការភាព (ដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ) | ១៣៨ | ២១ | ១៥៩ |
| មនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ | ១៤០ | ៤២២ | ៥៦២ |

តារាងទី១៣ បានបង្ហាញពីចំនួនបុគ្គលមានពិការភាព និងមនុស្សគ្មានអ្នកថែទាំ។ នៅក្នុងខេត្តព្រៃវែងមានបុគ្គលពិការភាព (អាយុក្រោម១៨ឆ្នាំ) ចំនួន២.៣៧៥នាក់ (ស្រី ១.០៨១នាក់) ពិការភាពអាចរកប្រាក់ចំណូលបានចំនួន ១.០៥៨នាក់ (ស្រី ៣៦៨នាក់) ពិការភាពមិនអាចរកប្រាក់ចំណូលបានចំនួន ២.៨២៨នាក់ (ស្រី ១.៣៩៦នាក់) និងមនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ចំនួន ៥៦២នាក់ (ស្រី ៤២២នាក់)។

## ក. អនីតិជនមានពិការភាព

*តារាងទី១៤៖ ចំនួនអនីតិជនមានពិការភាពតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួន | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| កញ្ជ្រៀច | ៨២ | ៥៥ | ១៣៧ | ៦ |
| កំចាយមារ | ៤៣០ | ៤២២ | ៨៥២ | ៣៦ |
| កំពង់ត្របែក | ៩៤ | ៧៥ | ១៦៩ | ៧ |
| បាភ្នំ | ៦២ | ៥៥ | ១១៧ | ៥ |
| ពាមជរ | ៧៥ | ៧៤ | ១៤៩ | ៦ |
| ពាមរក៍ | ៧១ | ៦២ | ១៣៣ | ៦ |
| ពារាំង | ៦៨ | ៦២ | ១៣០ | ៥ |
| ពោធិ៍រៀង | ៤៩ | ៤៨ | ៩៧ | ៤ |
| ព្រៃវែង | ២៦ | ១២ | ៣៨ | ២ |
| ព្រះស្ដេច | ៧៨ | ៦៣ | ១៤១ | ៦ |
| មេសាង | ១១៤ | ៤៨ | ១៦២ | ៧ |
| ស៊ីធរកណ្ដាល | ៤៩ | ២៦ | ៧៥ | ៣ |
| ស្វាយអន្ទរ | ៩៦ | ៧៩ | ១៧៥ | ៧ |
| **សរុបរួម** | **១.២៩៤** | **១.០៨១** | **២.៣៧៥** | **១០០** |

តារាងទី១៤៖ ចំនួនអនីតិជនមានពិការភាពតាមក្រុង/ស្រុក។ តារាងនេះបានបង្ហាញឱ្យឃើញថា ស្រុកកំចាយមារមានអនីតិជន (ជនអាយុក្រោម១៨ឆ្នាំ) ដែលមានពិការភាពច្រើនជាងគេ គឺ ៨៥២នាក់ (ស្រី ៤២២នាក់) ស្មើនឹង៣៦% បន្ទាប់មក គឺស្រុកស្វាយអន្ទរ មានចំនួន ១៧៥នាក់ (ស្រី ៧៩នាក់) ស្មើ ៧% ហើយបន្ទាប់មកទៀត គឺស្រុកកំពង់ត្របែក ១៦៩នាក់ (ស្រី ៧៥នាក់) ស្មើ៧% ស្រុកមេសាង ១៦២នាក់ (ស្រី ៤៨នាក់) ស្មើ៧% ស្រុកពាមជរ ១៤៩នាក់ (ស្រី ៧៤នាក់) ស្មើ៦% ស្រុកព្រះស្ដេច ១៤១នាក់ (ស្រី ៦៣នាក់) ស្មើ៦% ស្រុកកញ្ជ្រៀច ១៣៧នាក់ (ស្រី ៥៥នាក់) ស្មើ៦% ស្រុកពាមរក៍ ១៣៣នាក់ (ស្រី ៦២នាក់) ស្មើ៦% ស្រុកពារាំង ១៣០នាក់ (ស្រី ៦២នាក់) ស្មើ៥% ស្រុកបាភ្នំ ១១៧ នាក់ (ស្រី ៥៥នាក់) ស្មើ៥% ស្រុកពោធិ៍រៀង ៩៧នាក់ (ស្រី ៤៨នាក់) ស្មើ៤% ស្រុកស៊ីធរកណ្ដាល ៧៥ នាក់ (ស្រី ២៦នាក់) ស្មើ៣% និងចុងក្រោយគឺក្រុងព្រៃវែង ដែលមានតិចជាងគេ គឺ ៣៨នាក់ (ស្រី ១២ នាក់) ស្មើ២% នៃអនីតិជនដែលមានពិការភាពទាំងអស់។

## ខ. ពិការភាពអាចរកប្រាក់ចំណូលបាន

*តារាងទី១៥៖ ចំនួនជនមានពិការភាពដែលអាចរកប្រាក់ចំណូលបានតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួន | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| កញ្ជៀច | ៧៥ | ៤១ | ១១៦ | ១១ |
| កំចាយមារ | ៨៣ | ៤៥ | ១២៨ | ១២ |
| កំពង់ត្របែក | ២៧ | ៨ | ៣៥ | ៣ |
| បាភ្នំ | ៦៦ | ២៥ | ៩១ | ៩ |
| ពាមជរ | ៨ | ៦ | ១៤ | ១ |
| ពាមរក៍ | ២៧ | ២៣ | ៥០ | ៥ |
| ពារាំង | ៦៤ | ៤០ | ១០៤ | ១០ |
| ពោធិ៍រៀង | ៥៥ | ២៩ | ៨៤ | ៨ |
| ព្រៃវែង | ២៨ | ៣៣ | ៦១ | ៦ |
| ព្រះស្ដេច | ៤០ | ១១ | ៥១ | ៥ |
| មេសាង | ៥៧ | ២១ | ៧៨ | ៧ |
| ស៊ីធរកណ្ដាល | ៤៨ | ២៨ | ៧៦ | ៧ |
| ស្វាយអន្ទរ | ១១២ | ៥៨ | ១៧០ | ១៦ |
| **សរុបរួម** | **៦៩០** | **៣៦៨** | **១.០៥៨** | **១០០** |

តារាងទី១៥ បានបង្ហាញនូវចំនួនជនមានពិការភាពដែលមានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបាន (ឧទាហរណ៍ដូចជា ជាងម៉ូតូ ជាងកង់ ជាងកាត់សក់ ឬអ៊ុតសក់ជាដើម)។ យើងឃើញថា ជនមានពិការភាពដែលមានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបាននៅស្រុកស្វាយអន្ទរ គឺមានចំនួន ១៧០នាក់ (ស្រី ៥៨នាក់) ស្មើនឹង១៦% ដែលជាចំនួនច្រើនជាងគេ បើប្រៀបធៀបទៅនិងក្រុង/ស្រុកផ្សេងៗទៀតនៅក្នុងខេត្ត។ បន្ទាប់ពីស្រុកនេះ គឺស្រុកកំចាយមារ មាន១២៨នាក់ (ស្រី ៤៥នាក់) ស្មើ ១២% ស្រុកកញ្ជៀចមាន ១១៦នាក់ (ស្រី ៤១នាក់) ស្មើ១១% ស្រុកពារាំងមាន ១០៤នាក់ (ស្រី ៤០ នាក់) ស្មើ១០% ស្រុកបាភ្នំមាន ៩១នាក់ (ស្រី ២៥នាក់) ស្មើ៩% ស្រុកពោធិ៍រៀងមាន ៨៤នាក់ (ស្រី ២៩នាក់) ស្មើ៨% ស្រុកមេសាងមាន ៧៨នាក់ (ស្រី ២១នាក់) ស្មើ៧% ស្រុកស៊ីធរកណ្ដាលមាន ៧៦ នាក់ (ស្រី ២៨នាក់) ស្មើ៧% ក្រុងព្រៃវែងមាន ៦១នាក់ (ស្រី ៣៣នាក់) ស្មើ៦% ស្រុកព្រះស្ដេចមាន

៥១នាក់ (ស្រី ១១នាក់) ស្មើ៥% ស្រុកពាមរក៍មាន ៥០នាក់ (ស្រី ២៣នាក់) ស្មើ៥% ស្រុកកំពង់ត្របែកមាន ៣៥នាក់ (ស្រី ៨នាក់) ស្មើ៣%។ ចំណែកឯស្រុកពាមជរមានត្រឹមតែ ១១នាក់ (ស្រី ៦នាក់) ដែលស្មើនឹង១% នៃជនមានពិការភាពដែលអាចរកចំណូលបានដោយខ្លួនឯងតែប៉ុណ្ណោះ។

### គ. ពិការភាពមិនអាចរកប្រាក់ចំណូលបាន

*តារាងទី១៦៖ ចំនួនជនមានពិការភាពដែលមិនអាចរកប្រាក់ចំណូលបានតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួន | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| កញ្ជ្រៀច | ១៥៣ | ១៣៦ | ២៨៩ | ១០ |
| កំចាយមារ | ៥២ | ៧៣ | ១២៥ | ៥ |
| កំពង់ត្របែក | ១៤៦ | ១៣១ | ២៧៧ | ១០ |
| បាភ្នំ | ១៤៤ | ១១៩ | ២៦៣ | ៩ |
| ពាមជរ | ៦៥ | ៩៦ | ១៦១ | ៦ |
| ពាមរក៍ | ១០៨ | ១០៣ | ២១១ | ៧ |
| ពារាំង | ១៣៩ | ១១៦ | ២៥៥ | ៩ |
| ពោធិ៍រៀង | ១០៥ | ១០៣ | ២០៨ | ៧ |
| ព្រៃវែង | ៥៣ | ៣៣ | ៨៦ | ៣ |
| ព្រះស្ដេច | ៩០ | ៩៦ | ១៨៦ | ៧ |
| មេសាង | ១៥៦ | ១២៧ | ២៨៣ | ១០ |
| ស៊ីធរកណ្ដាល | ៦៨ | ១២២ | ១៩០ | ៧ |
| ស្វាយអន្ទរ | ១៥៣ | ១៤១ | ២៩៤ | ១០ |
| **សរុបរួម** | **១.៤៣២** | **១.៣៩៦** | **២.៨២៨** | **១០០** |

តារាងទី១៦ បានបង្ហាញនូវចំនួនជនមានពិការភាពដែលគ្មានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបាន។ យើងឃើញថា ជនមានពិការភាពដែលគ្មានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបាននៅស្រុកស្វាយអន្ទរ គឺមានចំនួន ២៩៤នាក់ (ស្រី ១៤១នាក់) ស្មើនឹង១០% ដែលជាចំនួនច្រើនជាងគេបើប្រៀបធៀបទៅនិងក្រុង/ស្រុកផ្សេងៗទៀតនៅក្នុងខេត្ត។ បន្ទាប់ពីស្រុកនេះ គឺស្រុកកញ្ជ្រៀចមានចំនួន

២៨៩នាក់ (ស្រី ១៣៦នាក់) ស្មើ១០% ស្រុកមេសាង ២៨៣នាក់ (ស្រី ១២៧នាក់) ស្មើ១០% ស្រុកកំពង់ត្របែក ២៧៧នាក់ (ស្រី ១៣១នាក់) ស្មើ១០% ស្រុកបាភ្នំ ២៦៣នាក់ (ស្រី ១១៩នាក់) ស្មើ៩% ស្រុកពារាំង ២៥៥នាក់ (ស្រី ១១៦នាក់) ស្មើ៩% ស្រុកពាមរក៍ ២១១នាក់ (ស្រី ១០៣នាក់) ស្មើ៧% ស្រុកពោធិ៍រៀង ២០៨នាក់ (ស្រី ១០៣នាក់) ស្មើ៧% ស្រុកស៊ីធរកណ្ដាល ១៩០នាក់ (ស្រី ១២២នាក់) ស្មើ៧% ស្រុកព្រះស្ដេច ១៨៦នាក់ (ស្រី ៩៦នាក់) ស្មើ៧% ស្រុកពាមជរ ១៦១នាក់ (ស្រី ៩៦នាក់) ស្មើ៦% ស្រុកកំចាយមារ ១២៥នាក់ (ស្រី ៧៣នាក់) ស្មើ៥%។ ចំណែកឯក្រុងព្រៃវែងមានត្រឹមតែ ៨៦នាក់ (ស្រី ៣៣នាក់) ស្មើ៣% នៃជនមានពិការភាពដែលមិនអាចរកចំណូលបានដោយខ្លួនឯងសរុបតែប៉ុណ្ណោះ។

## ឃ. ផលធៀបបុគ្គលពិការភាពអាចរកចំណូល និងមិនអាចរកចំណូលបាន




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

បើមើលទៅលើផលធៀបរវាងជនមានពិការភាពដែលអាចរកចំណូល និងមិនអាចរកចំណូលដោយខ្លួនឯងបានវិញ (រូបភាពទី១៨) ឃើញថា ស្រុកកញ្ជ្រៀច កំចាយមារ ពារាំង ពោធិ៍រៀង ព្រៃវែង និងស្រុកស្វាយអន្ទរ មានអត្រាភាគរយនៃជនមានពិការភាពដែលមានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបាន ខ្ពស់ជាង ស្រុកកំពង់ត្របែក ពាមជរ ពាមរក៍ ព្រះស្ដេច និងស្រុកមេសាង ខណៈដែលស្រុកពីរទៀត (បាភ្នំ និង ស៊ីធរកណ្ដាល) មានចំនួនស្មើគ្នា។

## ង. ពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ

*តារាងទី១៧៖ ចំនួនជនមានពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួន | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| កញ្ជ្រៀច | ៧ | ០ | ៧ | ៤ |
| កំចាយមារ | ២៥ | ៦ | ៣១ | ១៩ |
| កំពង់ត្របែក | ១០ | ២ | ១២ | ៨ |
| បាភ្នំ | ៩ | ០ | ៩ | ៦ |
| ពាមជរ | ១ | ០ | ១ | ១ |
| ពាមរក៍ | ២ | ០ | ២ | ១ |
| ពារាំង | ១១ | ៣ | ១៤ | ៨ |
| ពោធិ៍រៀង | ១ | ០ | ១ | ១ |
| ព្រៃវែង | ១៥ | ៣ | ១៨ | ១១ |
| ព្រះស្ដេច | ៩ | ០ | ៩ | ៦ |
| មេសាង | ២១ | ៥ | ២៦ | ១៦ |
| ស៊ីធរកណ្ដាល | ១០ | ២ | ១២ | ៨ |
| ស្វាយអន្ទរ | ១៧ | ០ | ១៧ | ១១ |
| **សរុបរួម** | **១៣៨** | **២១** | **១៥៩** | **១០០** |

តារាងទី១៧ បានបង្ហាញនូវចំនួនជនមានពិការភាពដោយសារគ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះ តាមក្រុង/ស្រុកនីមួយៗដែលមាននៅក្នុងខេត្ត។ ប្រជាជនសរុបចំនួន១៥៩នាក់ បានរងគ្រោះថ្នាក់ដោយសារគ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះ ក្នុងនោះយើងឃើញថា ស្រុកកំចាយមារមានអ្នករងគ្រោះដោយសារបញ្ហានេះច្រើនជាងគេ គឺ ៣១នាក់ (ស្រី ៦នាក់) ស្មើ១៩% បន្ទាប់មក គឺស្រុកមេសាង ២៦នាក់ (ស្រី ៥នាក់) ស្មើ១៦% បន្ទាប់មកទៀត គឺក្រុងព្រៃវែង ១៨នាក់ (ស្រី ៣នាក់) ស្មើ១១% ស្រុកស្វាយអន្ទរ ១៧នាក់ (ស្រី ០នាក់) ស្មើ១១% ស្រុកពារាំង ១៤នាក់ (ស្រី ៣នាក់) ស្មើ៨% ស្រុកកំពង់ត្របែក និងស្រុកស៊ីធរកណ្ដាលមានចំនួនស្មើគ្នា គឺ ១២នាក់ (ស្រី ២នាក់) ស្មើ៨% ចំណែកស្រុកបាភ្នំ និងស្រុកព្រះស្ដេចវិញក៏មានចំនួនអ្នកពិការភាពដោយសារគ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះស្មើគ្នាដែរ គឺ ៩នាក់ (ស្រី ០នាក់)

ស្មើ៦% រីឯស្រុកកញ្ជៀចមាន ៧នាក់ (ស្រី ០នាក់) ស្មើ៤% និងចុងក្រោយ គឺស្រុកពាមរក៍ ពាមជរ និង ស្រុកពោធិ៍រៀងមានចំនួន ៤នាក់ (ស្រី ០នាក់) ដែលស្មើនឹង ៣% នៃចំនួនជនមានពិការភាពដោយសារ គ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះនៅក្នុងខេត្តទាំងមូល។

### ច. មនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់

ការរស់នៅដោយមានគ្នាសំណាក់អាស្រ័យជាមួយ គឺជារឿងសំខាន់ ពិសេសនៅពេលមានជំងឺ ឈឺថ្កាត់ ឬពេលស្ថិតនៅក្នុងវ័យជរា។ ទោះជាមិនចង់រស់នៅឯកាយ៉ាងណាក្តី តែព្រហ្មលិខិតបានកម្រិត ចារមកហើយ យើងត្រូវតែហ៊ានទទួលយក និងតស៊ូ ព្យាយាម ជំនះគ្រប់ឧបសគ្គ ដរាបដល់ដង្ហើមចុង ក្រោយ។

*តារាងទី១៨៖ ចំនួនមនុស្សចាស់គ្មានអ្នកថែទាំ ឬផ្គត់ផ្គង់តាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួន | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| កញ្ជៀច | ១០ | ៣៧ | ៤៧ | ៨ |
| កំចាយមារ | ២១ | ៣១ | ៥២ | ៩ |
| កំពង់ត្របែក | ១៥ | ៣២ | ៤៧ | ៨ |
| បាភ្នំ | ១៩ | ៣០ | ៤៩ | ៩ |
| ពាមជរ | ០ | ៥ | ៥ | ១ |
| ពាមរក៍ | ៥ | ២១ | ២៦ | ៥ |
| ពារាំង | ១៤ | ២៨ | ៤២ | ៨ |
| ពោធិ៍រៀង | ១ | ២២ | ២៣ | ៤ |
| ព្រៃវែង | ០ | ២ | ២ | ០ |
| ព្រះស្តេច | ២៣ | ៦៥ | ៨៨ | ១៦ |
| មេសាង | ១០ | ៧៥ | ៨៥ | ១៥ |
| ស៊ីធរកណ្តាល | ១៤ | ៣០ | ៤៤ | ៨ |
| ស្វាយអន្ទរ | ៨ | ៤៤ | ៥២ | ៩ |
| **សរុបរួម** | **១៤០** | **៤២២** | **៥៦២** | **១០០** |

ជាក់ស្តែង នៅក្នុងតារាងទី១៨ខាងលើ បានបង្ហាញថា៖ មានមនុស្សចាស់ចំនួន ៥៦២នាក់ (ស្រី ៤២២នាក់) ដែលបាននិងកំពុងរស់រងវេទនាដោយគ្មានអ្នកផ្គត់ផ្គង់ និងមើលថែទាំ។ ក្នុងនោះយើងក៏ឃើញផងដែរថា ស្រុកព្រះស្តេច មានមនុស្សចាស់គ្មានអ្នកផ្គត់ផ្គង់ និងមើលថែទាំ ៨៨នាក់ (ស្រី ៦៥នាក់) ស្មើនឹង ១៦% ដែលជាចំនួនច្រើនជាងគេ បើធៀបទៅនឹងក្រុង/ស្រុកផ្សេងៗទៀតនៅក្នុងខេត្តនេះ។ ស្រុកមេសាង មានចំនួន ៨៥នាក់ (ស្រី ៧៥នាក់) ស្មើ១៥ ដែលជាស្រុកបន្ទាប់កំពុងជួបនូវបញ្ហានេះ។ បន្ទាប់ពីនេះ គឺស្រុកស្វាយអន្ទរ ៥២នាក់ (ស្រី ៤៤នាក់) ស្មើ៩% ស្រុកកំចាយមារ ៥២នាក់ (ស្រី ៣១នាក់) ស្មើ៩% ស្រុកបាភ្នំ ៤៩នាក់ (ស្រី ៣០នាក់) ស្មើ៩% ស្រុកកញ្ជ្រៀច ៤៧នាក់ (ស្រី ៣៧នាក់) ស្មើ៨% ស្រុកកំពង់ត្របែក ៤៧នាក់ (ស្រី ៣២នាក់) ស្មើ៨% ស្រុកស៊ីធរកណ្តាល ៤៤នាក់ (ស្រី ៣០នាក់) ស្មើ៨% ស្រុកពារាំង ៤២នាក់ (ស្រី ២៨នាក់) ស្មើ៨% ស្រុកពាមរក៍ ២៦នាក់ (ស្រី ២១នាក់) ស្មើ៥% ស្រុកពោធិ៍រៀង ២៣នាក់ (ស្រី ២២នាក់) ស្មើ៤% ស្រុកពាមជរ ៥នាក់ (ស្រី ៥នាក់) ស្មើ១% រីឯក្រុងព្រៃវែងមានចំនួនតិចជាងគេ គឺមិនដល់ ១% ផង (ស្រី ២នាក់, ប្រុស ០នាក់) បើធៀបទៅនឹងក្រុង/ស្រុកផ្សេងៗទៀតដែលនៅក្នុងខេត្តនេះ។

## ២.៤. អាពាហ៍ពិពាហ៍ និងការលែងលះ

អាពាហ៍ពិពាហ៍ ត្រូវបានកំណត់និយមន័យខុសៗគ្នាទៅតាមអង្គភាព ឬដោយផ្អែកទៅលើវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី សាសនា មជ្ឈដ្ឋានជុំវិញ ឬបុគ្គលផ្ទាល់ខ្លួនជាដើម។ នៅក្នុងរបាយការណ៍នេះ និយមន័យនៃអាពាហ៍ពិពាហ៍ត្រូវបានកំណត់ថា៖ ជាកិច្ចសន្យាសង្គម និងច្បាប់រវាងបុគ្គលពីរនាក់ដែលបង្រួបបង្រួមជីវិតរបស់ពួកគេតាមផ្លូវច្បាប់ផ្នែកសេដ្ឋកិច្ច និងខាងអារម្មណ៍។ កិច្ចសន្យាអាពាហ៍ពិពាហ៍ជាធម្មតាបញ្ជាក់ថា ប្តីប្រពន្ធនោះមានកាតព្វកិច្ចផ្លូវច្បាប់ចំពោះគ្នាទៅវិញទៅមកពេញមួយជីវិត ឬរហូតដល់ពួកគេសម្រេចចិត្តលែងលះគ្នា។

*រូបភាពទី១៩៖ ចំនួនអ្នករៀបអាពាហ៍ពិពាហ៍ និងលែងលះតាមប្រភេទការងារ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី១៩ បង្ហាញនូវចំនួនអ្នករៀបអាពាហ៍ពិពាហ៍ និងអ្នកលែងលះគ្នាដោយបែងចែកតាមប្រភេទនៃការងារ។ យើងឃើញថា អ្នកមានការងារជាពលករ/កម្មករ/កសិករ មានចំនួនអ្នករៀបអាពាហ៍ពិពាហ៍ (១៦.៧៤២នាក់) ខ្ពស់ជាង៤ដងនៃអ្នកមានការងារជាមន្ត្រីរាជការ (៤.៨៨៩នាក់) ខណៈដែលអ្នកមានវិជ្ជាជីវៈមាន ៤.០៩៤នាក់ អ្នកជំនួញមាន ២.១៧២នាក់ និងអ្នកនយោបាយមាន ២៤២នាក់។ បើមើលទៅលើអត្រានៃអ្នកលែងលះវិញឃើញថា អ្នកមានវិជ្ជាជីវៈមានចំនួនច្រើនជាងគេ គឺ ៦១៨នាក់ បន្ទាប់មក គឺអ្នកមានការងារជាពលករ/កម្មករ/កសិករមានចំនួន ៣៥៨នាក់ និងអ្នកមានការងារជាមន្ត្រីរាជការមានចំនួន ២៤២នាក់។ ចំណែកឯអ្នកមានការងារជាអ្នកជំនួញ និងអ្នកនយោបាយមិនសូវមានអ្នកលែងលះទេ។ តាមរូបភាពភាពនេះ អ្នកមានការងារជាអ្នកជំនួញមាន ២០នាក់ ឯអ្នកអ្នកនយោបាយមានត្រឹមតែ ១១នាក់ប៉ុណ្ណោះ។

## ២.៥. ការប្រើប្រាស់ទឹក និងអនាម័យ

ទឹក គឺជាវត្ថុរាវធម្មតាមួយប្រភេទនៅលើផែនដី។ វាមាន ៧១,៤% នៃផ្ទៃផែនដី គ្របដណ្ដប់ទៅដោយទឹក។ ទឹកស្អាតដែលសព្វថ្ងៃគេនិយមហៅថា ទឹកបរិសុទ្ធ ពុំមានក្លិន រសជាតិ និងពណ៌ទេ។ ឈ្មោះនៃទឹក ត្រូវបានគេហៅតាមទីកន្លែងរបស់វាដូចជា ទឹកបឹង ទឹកទន្លេ ទឹកសមុទ្រ ឬទឹកភ្លៀងជាដើម។

## ក. ការប្រើប្រាស់ទឹក




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី២០ និង២១ គឺជាប្រភពទឹកចម្បងសម្រាប់បរិភោគក្នុងគ្រួសារ។ រូបភាពនេះបាន បង្ហាញឱ្យឃើញថា គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងសម្រាប់បរិភោគមានចំនួនច្រើនជាងគេ គឺ ២០៤.៥៤២គ្រួសារ ស្មើនឹង៦៩% បន្ទាប់មក គឺទឹកស្អាត (ទឹកទុយោ) ៦១.១៥៥គ្រួសារ ស្មើនឹង ២១% បន្ទាប់មកទៀត គឺប្រភពទឹកផ្សេងៗទៀត ២៣.៦៤៥គ្រួសារ ស្មើ៨% ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ ៤.៩៨៥ គ្រួសារ ស្មើ២% ចំណែកឯទឹកភ្លៀងមានចំនួនតិចជាងគេ ដែលមាន ១.២៥៩គ្រួសារ (0%) បើប្រៀប ធៀបទៅនឹងប្រភពទឹកសម្រាប់បរិភោគផ្សេងៗទៀត។

## ខ. បង្គន់អនាម័យ

អនាម័យ គឺជាកត្តាសំខាន់សម្រាប់សុខភាព។ ការប្រើប្រាស់នូវបង្គន់អនាម័យបានត្រឹមត្រូវ វាគឺ ជាផ្នែកមួយក្នុងការជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសង្គមជាតិ តាមរយៈការកាត់បន្ថយ ជំងឺនានា ជាពិសេសគឺជំងឺរាករូស។ តាមលទ្ធផលជំរឿនឆ្នាំ២០១៩ ការប្រើប្រាស់បង្គន់អនាម័យនៅកម្ពុជា មាន ៨២,៨% គឺមានការរីកចម្រើនជាខ្លាំងក្នុងរយៈពេលមួយទស្សវត្សរ៍ចុងក្រោយនេះ។

*រូបភាពទី២២៖ ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

ជាក់ស្តែង រូបភាពទី២២ ក៏បានបង្ហាញដែរថា ៨៦% នៃគ្រួសារសរុបទូទាំងខេត្ត គឺមានបង្គន់ អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន។ ថ្វីដ្បិតតែនេះជាតួលេខដែលឈានដល់ការប្រកាសខេត្តឈប់បន្ទោបង់ ពាសវាលពាសកាល (ODF) ក៏ពិតមែន ក៏នៅមានគ្រួសារ ១៤% ទៀតមិនទាន់មានបង្គន់អនាម័យប្រើ

ប្រាស់ផ្ទាល់ខ្លួននៅឡើយ ដូច្នោះអជ្ញាធរ ដែលពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានគួរតែខិតខំជំរុញបន្ថែមទៀត ពិសេសគឺប្រជាពលរដ្ឋខ្លួនឯងផ្ទាល់គួរតែចេះភ្ញាក់រឭកដោះស្រាយនូវបញ្ហានេះ។

### គ. គ្រួសារគ្មានផ្ទះសំបែង




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

ប្រជាជនគ្មានផ្ទះសំបែង និងគ្មានដីធ្លី ក៏ជាបញ្ហាប្រឈមមួយក្នុងការអភិវឌ្ឍប្រទេសជាតិផងដែរ។ រូបភាពទី២៣ និង២៤ បានបង្ហាញថា នៅក្នុងខេត្តព្រៃវែងមានប្រជាជនរស់នៅលើដីសាធារណៈចំនួន ១.៦៧៤គ្រួសារ (០,៦%) ខណៈដែល ៩១១គ្រួសារ (០,៣%) ទៀត កំពុងគ្មានផ្ទះសំបែងសម្រាប់ស្នាក់នៅ។

## ២.៦. បរិស្ថាន និងធនធានធម្មជាតិ

### ក. គ្រោះធម្មជាតិ

នៅប្រទេសកម្ពុជា ខ្យល់ព្យុះ ទឹកជំនន់ និងរន្ទះបាញ់ គឺជាគ្រោះមហន្តរាយធម្មជាតិចម្បងដែលធ្វើឱ្យបាត់បង់ជីវិតមនុស្សសត្វ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ខណៈដែលគ្រោះរាំងស្ងួត ការបាក់ដី/ស្រុតដីចូលទន្លេ ព្រៃក ឬស្ទឹង បានបង្កឱ្យមានទុក្ខវេទនាយ៉ាងខ្លាំងដល់ប្រជាជន ជាពិសេសចំពោះប្រជាកសិករ។ ការផ្លាស់ប្ដូរអាកាសធាតុនឹងធ្វើឱ្យស្ថានភាពនេះកាន់តែលំបាក ដោយរដូវប្រាំងមានអាកាសធាតុកាន់តែក្ដៅហួតហែង និងរដូវវស្សាមានភ្លៀងធ្លាក់ជោគជាំ និងខ្យល់ព្យុះកាន់តែខ្លាំង។

*តារាងទី១៩៖ ផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ*

| គ្រោះធម្មជាតិ | ផលប៉ះពាល់ | |
|---|---|---|
| | គ្រួសារ | ផ្ទៃដី (ហិកតា) |
| រាំងស្ងួត | ៣.៧៤៨ | ៤.៨១៣ |
| ទឹកជំនន់ | ១.៩៥៦ | ១.៨៨៥ |
| បាក់ ឬស្រុតដី | ៣៥៧ | ៦៨៦ |
| ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ | ៩៤ | ៣៣ |
| គ្រោះធម្មជាតិផ្សេងទៀត | ៨ | ២៤ |

តារាងទី១៩៖ ផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ។ តារាងនេះបានបង្ហាញថា គ្រោះរាំងស្ងួតបានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីដាំដុះចំនួន ៤.៨១៣ហិកតា និង ៣.៧៤៨គ្រួសារ។ គ្រោះទឹកជំនន់បានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន ១.៨៨៥ហិកតា និង១.៩៥៦គ្រួសារ។ ការបាក់ដី ឬស្រុតដីរងផលប៉ះពាល់ចំនួន ៦៨៦ហិកតា និង ៣៥៧គ្រួសារ ហើយខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ និងគ្រោះ

ធម្មជាតិផ្សេងទៀតក៏បានរួមចំណែកក្នុងការបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន ៥៧ហិកតា និង ១០២គ្រួសារផងដែរ។

### ខ. ការបំពុលបរិស្ថាន និងកាកសំណល់

នៅកម្ពុជា កំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស កំពុងបង្កឱ្យមានការបំពុលបរិស្ថាន។ សកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច បាននិងកំពុងបង្កផលវិបាកដល់បរិស្ថាន មនុស្ស និងសត្វផងដែរ។

*តារាងទី២០៖ ផលប៉ះពាល់ដោយសារការបំពុលបរិស្ថាន និងកាកសំណល់*

| ការបំពុលបរិស្ថាន និងកាកសំណល់ | ផលប៉ះពាល់ | |
|---|---|---|
| | គ្រួសារ | ផ្ទៃដី (ហិកតា) |
| ទីតាំងចោលសំរាម | ៨៤ | ៥៨ |
| ទីតាំងចោលកាកសំណល់ឧស្សាហកម្ម | ៣៦ | ២៣ |
| ទីតាំងរោងចក្រ | ៥ | ១២៥ |
| ការប្រើប្រាស់ជីគីមី/ថ្នាំពុលកសិកម្ម | ២៣០.៣០២ | ២៨១.៥៤១ |

តាមតារាងទី២០ យើងឃើញថា ទីតាំងចោលសំរាមបានបង្កឱ្យមានផលប៉ះពាល់ដល់មនុស្ស ៨៤គ្រួសារ លើផ្ទៃដី ៥៨ហិកតា ឯទីតាំងចោលសំណល់ឧស្សាហកម្មបានប៉ះពាល់ដល់ ៣៦គ្រួសារ លើផ្ទៃដី ២៣ហិកតា រីឯទីតាំងរោងចក្របានប៉ះពាល់ដល់ ៥គ្រួសារ លើផ្ទៃដី ១២៥ហិកតា។ ចំណែកឯការប្រើប្រាស់ជីគីមី/ថ្នាំពុលកសិកម្មវិញបានបង្កជាផលវិបាកយ៉ាងធ្ងន់ធ្ងរដល់សុខភាពជីវិតមនុស្ស សត្វ រុក្ខជាតិ និងគុណភាពដី ដោយយោងតាមតារាងនេះ ឃើញថា មនុស្សចំនួន ២៣០.៣០២គ្រួសារ និងផ្ទៃដី ២៨១.៥៤១ហិកតា បានរងផលប៉ះពាល់។

## គ. ការប្រើប្រាស់អុស ធ្យូង

*រូបភាពទី២៥៖ ភាគរយគ្រួសារប្រើប្រាស់អុស/ធ្យូងសម្រាប់ចម្អិន*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

ការចម្អិនអាហារ គឺជាតម្រូវការចាំបាច់ និងមិនអាចខ្វះបានសម្រាប់ជីវិតរស់នៅរបស់មនុស្ស។ ការប្រើប្រាស់អុស ធ្យូង ក៏ត្រូវបានប្រើជាប្រភពថាមពលចម្បងមួយក្នុងការចម្អិន។ រូបភាពទី២៥ បានបង្ហាញថា ៦៦% នៃប្រជាជនដែលរស់នៅក្នុងខេត្តព្រៃវែងកំពុងប្រើប្រាស់អុស ធ្យូង ខណៈដែល ៣៤% ទៀតបានប្រើប្រាស់ប្រភពថាមពលផ្សេងទៀត ដូចជា ហ្គាស សម្រាប់ចម្អិនម្ហូបអាហារ។

## ឃ. ព្រៃឈើ

*តារាងទី២១៖ ផ្ទៃដីព្រៃឈើ និងការកាប់ឆ្ការព្រៃ*

| ព្រៃឈើ | ផ្ទៃដី (ហិកតា) |
|---|---|
| ព្រៃឈើ | ១.៧០៨ |
| ដាំកូនឈើ | ១៧០ |
| កាប់ឆ្ការព្រៃឈើ | ១៦ |

តារាងទី២១ បានបង្ហាញថា នៅក្នុងខេត្តព្រៃវែងមានផ្ទៃដីព្រៃឈើគ្របដណ្តប់ចំនួន ១.៧០៨ហិកតា និងផ្ទៃដីដាំកូនព្រៃឈើចំនួន ១៧០ហិកតា។ ទន្ទឹមនោះ ក៏មាននូវការកាប់រានទន្រ្ទានព្រៃឈើចំនួន ១៦ ហិកតា ដើម្បីយកដីធ្វើកសិកម្ម និងជាកម្មសិទ្ធិផ្ទាល់ខ្លួនផងដែរ។

## ២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច

### ២.៧.១. សន្តិសុខសង្គម

អសន្តិសុខសង្គម សំដៅលើការលួច ឆក់ ប្លន់ ចាប់ជម្រិត ឧក្រិដ្ឋកម្ម ការប្រើប្រាស់គ្រឿងញៀន និងជម្លោះដីធ្លីនៅក្នុងមូលដ្ឋានជាដើម។ ចំពោះករណីទាំងអស់នេះ ទោះបីជាមានចំនួនកើតឡើងច្រើនយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាល និងអាជ្ញាធរខេត្តព្រៃវែងបានខិតខំដោះស្រាយបានមួយចំនួនធំផងដែរ ដូចមានតួលេខបញ្ជាក់ខាងក្រោមនេះ៖

#### ក. អសន្តិសុខសង្គម

*រូបភាពទី២៦៖ អសន្តិសុខ និងការដោះស្រាយ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី២៦ បានបង្ហាញពីបញ្ហាអសន្តិសុខ និងការដោះស្រាយ។ រូបភាពនេះបានបង្ហាញថា ក្នុងចំណោមករណីអសន្តិសុខដែលកើតមាននៅក្នុងខេត្តព្រៃវែងទាំងអស់ បញ្ហាជម្លោះដីធ្លីមានការកើតឡើងច្រើនជាងគេ ១.៦៣២ករណី ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏អាជ្ញាធរព្យាយាមដោះស្រាយអស់ ១.៣៦៧ករណីដែរ។ ចំពោះបញ្ហាប្រជាពរដ្ឋឈ្លោះទាស់ទែងគ្នា បានកើតឡើង ១.២៤៣ករណី ក្នុងនោះដោះស្រាយបានចំនួន ១.១៣៥ករណី។ ដោយឡែកករណីលួច បានកើតឡើងចំនួន ១៨៣ករណី ក្នុងនោះដោះស្រាយបាន ១០៤ករណី បញ្ហាឃាតកម្ម ប្លន់ ចាប់ជម្រិត មានចំនួន ៨ករណី និងដោះស្រាយបានចំនួន ៣ករណីផងដែរ។ ចំណែកឯករណីឧក្រិដ្ឋកម្មវិញមាន ៧ករណី ដែលដោះស្រាយបានតែ ២ករណី ប៉ុណ្ណោះ។

## ខ. អំពើហិង្សាក្នុងគ្រួសារ និងគ្រឿងញៀន

*រូបភាពទី២៧៖ ករណីអំពើហិង្សាក្នុងគ្រួសារ និងការប្រើប្រាស់គ្រឿងញៀន*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី២៧៖ ក្នុងចំណោមគ្រួសារសរុប (២៩៥.៥៨៦គ្រួសារ) ដែលរស់នៅខេត្តព្រៃវែង គឺមាន ៦៥៩គ្រួសារ (០,២%) បានទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ និង ៥៣៣គ្រួសារ (០,២%) ទៀតមានសមាជិកកំពុងប្រើប្រាស់គ្រឿងញៀន។

### គ. ស្ត្រីរងគ្រោះដោយការចាប់រំលោភ និងការជួញដូរ

*រូបភាពទី២៨៖ ចំនួនស្ត្រីរងគ្រោះដោយការចាប់រំលោភ និងការជួញដូរ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី២៨ បានបង្ហាញថា មានស្ត្រីរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទចំនួន ៥១ នាក់ ក្នុងនោះភាគច្រើនគឺជាក្មេងស្រីមានអាយុក្រោម១៨ឆ្នាំ ចំណែកឯការជួញដូរស្ត្រីវិញមាន ៤នាក់ (ក្រោមអាយុ១៨ឆ្នាំមាន២នាក់ និងចាប់ពី១៨ឆ្នាំឡើងមាន២នាក់)។

## ២.៧.២. សេដ្ឋកិច្ចគ្រួសារ

នៅក្នុងប្រទេសកម្ពុជាយើងមានសកម្មភាពអាជីវកម្មជាច្រើន ដែលប្រជាជនធ្វើសកម្មភាពដើម្បីរកស៊ីចិញ្ចឹមជីវិតដោយមិនរាប់ចូលសកម្មភាពកសិកម្ម និងមុខរបរអាជីពដូចជា គ្រូពេទ្យ គ្រូបង្រៀន ប៉ូលីស ទាហ៊ាន ... ជាដើម។ ក្នុងចំណោមសកម្មភាពអាជីវកម្មទាំងអស់នោះ យើងបានជ្រើសរើសសកម្មភាពអាជីវកម្មសំខាន់ៗចំនួន១៥អាជីវកម្ម ដើម្បីយកមកបង្ហាញសម្រាប់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។

## ក. សកម្មភាពអាជីវកម្ម

*តារាងទី២២៖ សកម្មភាពអាជីវកម្មចម្បងតាមគ្រួសារ*

| សកម្មភាពអាជីវកម្ម | ចំនួនគ្រួសារ |
|---|---|
| ហាងលក់គ្រឿងទេស/គេសជ្ជៈ | ៧.៣១២ |
| តូបលក់សាំង | ៣.៨៣៨ |
| ម៉ាស៊ីនកិនស្រូវ | ២.៤៦០ |
| ជួសជុលកង់/ម៉ូតូ | ១.៨២៨ |
| បិតស្រា | ១.២៧៨ |
| ហាងកាត់សក់/អ៊ុតសក់ | ១.១៥៧ |
| ហាងលក់ថ្នាំពេទ្យ/គ្លីនិក | ៥៧៤ |
| គ្រឿងសំណង់ | ៥៦៤ |
| ស្ថានីយ៍ប្រេងឥន្ធនៈ | ៤៦៤ |
| ជួសជុលគ្រឿងអេឡិចត្រូនិច | ៣៧២ |
| ជួសជុលរថយន្ត | ៣៥៦ |
| ជួសជុលឧបករណ៍/គ្រឿងម៉ាស៊ីនកសិកម្ម | ៣៣៧ |
| កាត់កញ្ចក់/ជាងដែក | ៣២៣ |
| ផលិតគ្រឿងសង្ហារឹមពីឈើ | ២១៩ |
| ផ្ទះសំណាក់ | ១១៦ |
| ភោជនីយដ្ឋាន | ៧៥ |
| សណ្ឋាគារ | ១១ |
| អាជីវកម្មផ្សេងទៀត | ៦៣៦ |
| **សរុប** | **២១.៩២០** |

ក្រៅពីការប្រកបរបរកសិកម្ម និងមុខរបរអាជីព ការធ្វើអាជីវកម្មបានដើរតួបន្ថែមយ៉ាងសំខាន់ក្នុងការលើកស្ទួយជីវភាពគ្រួសារ។ តាមតារាងទី២២ ឃើញថា នៅក្នុងខេត្តព្រៃវែងរបរអាជីវកម្មភាគច្រើនប្រជាជនធ្វើទៅលើការលក់ចាប់ហួយ/គ្រឿងទេស/គេសជ្ជៈ (៧.៣១២កន្លែង) បន្ទាប់មក គឺលក់សាំងដប (៣.៨៣៨កន្លែង) និងរោងម៉ាស៊ីនកិនស្រូវ (២.៤៦០កន្លែង)។ ចំណែកឯសណ្ឋាគារមាន ១១កន្លែងដែលជាចំនួនតិចជាងគេបំផុតក្នុងចំណោមប្រភេទមុខរបរអាជីវកម្មទាំងអស់។




ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១

រូបភាពទី២៩ បានបង្ហាញថា មានតែ ៧% នៃគ្រួសារសរុប (២៩៥.៥៨៦គ្រួសារ) ប៉ុណ្ណោះដែលបានប្រកបរបរអាជីវកម្ម។

## ខ. អ្នកធ្វើការក្នុងអាជីវកម្ម




ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១

*រូបភាពទី៣១៖ ភាគរយអ្នកធ្វើការក្នុងអាជីវកម្ម*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣០ និង៣១ និយាយពីចំនួនអ្នកធ្វើការក្នុងអាជីវកម្ម។ យើងឃើញថា ស្ទើរតែគ្រប់ប្រភេទនៃអាជីវកម្មទាំងអស់ មនុស្សប្រុសបានចូលរួមចំណែកច្រើនជាងមនុស្សស្រី។ បើសរុបចំនួនអ្នកធ្វើការក្នុងអាជីវកម្មទាំងនេះវិញ មាន ៣៧.០៥៤នាក់ ក្នុងនោះស្រីមាន ១៧.៨៣១នាក់ ស្មើនឹង ៤៨% ដែលជាមធ្យមមានមនុស្សប្រហែលជា ២នាក់ ធ្វើការក្នុងមួយអាជីវកម្ម ឬមួយកន្លែង។

## ២.៧.៣. សកម្មភាពនៃការអភិវឌ្ឍ

### ក. ការអភិវឌ្ឍកសិកម្ម និងនេសាទ

*រូបភាពទី៣២៖ ចំនួនសកម្មភាពអភិវឌ្ឍកសិកម្ម និងនេសាទ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣២ បង្ហាញអំពីចំនួនសកម្មភាពនៃការអភិវឌ្ឍផ្នែកកសិកម្ម និងនេសាទ ដែលក្នុងនោះ ចំនួនសកម្មភាពអភិវឌ្ឍទៅលើការដាំដុះមានច្រើនជាងគេ ដែលមានរហូតទៅដល់ ៩៦សកម្មភាព បន្ទាប់មកគឺការអភិវឌ្ឍទៅលើប្រព័ន្ធធារាសាស្ត្រ៦៨សកម្មភាព បសុសត្វ/បសុបក្សី៣៥សកម្មភាព វារីវប្បកម្ម២៣សកម្មភាព និងចុងក្រោយគឺសកម្មភាពអភិវឌ្ឍទៅលើផ្នែកនេសាទ ដែលមាន ១៩សកម្មភាព។

### ខ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម

*រូបភាពទី៣៣៖ ចំនួនសកម្មភាពអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣៣ បង្ហាញអំពីចំនួនសកម្មភាពនៃការអភិវឌ្ឍទៅលើវិស័យឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ ចំពោះចំនួនសកម្មភាពអភិវឌ្ឍលើវិស័យធំៗទាំងពីរខាងលើមាន៖ ការអភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធចំនួន ២១០សកម្មភាព និងការអភិវឌ្ឍលើវិស័យឧស្សាហកម្មមានចំនួន ១៤សកម្មភាព។

## ២.៨. វិស័យអប់រំ និងសេវាសង្គម

### ២.៨.១. វិស័យអប់រំ

វិស័យអប់រំនៅក្នុងសៀវភៅនេះ គឺគ្រាន់តែសំដៅលើចំនួនសាលារៀន និងចម្ងាយពីទីតាំងភូមិទៅកន្លែងផ្តល់សេវាអប់រំទាំងនោះតែប៉ុណ្ណោះ។ សាលារៀនមានតាមកម្រិតដូចជា៖ មត្តេយ្យសិក្សា សាលាបឋមសិក្សា សាលាអនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យ (ទាំងរដ្ឋ និងឯកជន)។

#### ក. គ្រឹះស្ថានសិក្សា

*តារាងទី២៣៖ ចំនួនសាលារៀនបែងចែកតាមប្រភេទវិស័យ*

| កម្រិតអប់រំ | វិស័យ | | |
|---|---|---|---|
| | រដ្ឋ | ឯកជន | សហគមន៍ |
| មត្តេយ្យសិក្សា | ៣៩៩ | ៣ | ២៩៦ |
| បឋមសិក្សា | ៥៤៧ | ១ | 0 |
| អនុវិទ្យាល័យ | ៩៣ | 0 | 0 |
| វិទ្យាល័យ | ៣២ | ១ | 0 |
| សាកលវិទ្យាល័យ | ១ | 0 | 0 |

*ប្រភព៖ កម្មវិធីវិនិយោគបីឆ្នាំរំកិលឆ្នាំ២០២៣-២០២៥របស់ខេត្តព្រៃវែង*

តារាងទី២៣ បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាតាមកម្រិត និងបានបែងចែកទៅតាមវិស័យនីមួយៗ។ ចាប់ពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សាមានគ្រឹះស្ថានសិក្សាចំនួន ១.៣៧៣កន្លែង ក្នុងនោះ មត្តេយ្យសិក្សាមានចំនួន ៦៩៨កន្លែង (សាលារដ្ឋមាន៣៩៩កន្លែង ឯកជនមាន៣កន្លែង និងសាលាសហគមន៍មាន២៩៦កន្លែង) បឋមសិក្សាមានចំនួន ៥៤៨កន្លែង (សាលារដ្ឋមាន៥៤៧កន្លែង និងឯកជនមាន១កន្លែង) អនុវិទ្យាល័យមានចំនួន ៩៣កន្លែង (សាលារដ្ឋទាំងអស់) វិទ្យាល័យមានចំនួន

៣៣កន្លែង (សាលារដ្ឋមាន៣២កន្លែង និងឯកជនមាន១កន្លែង) និងមានសាកលវិទ្យាល័យរដ្ឋចំនួន ១ កន្លែងផងដែរ។

## ខ. ចម្ងាយពីភូមិទៅសាលារៀន

ចម្ងាយមធ្យមពីភូមិទៅសាលារៀន គឺមានន័យថាជាចម្ងាយចំណុចកណ្តាលពីភូមិមួយ ទៅភូមិណាមួយផ្សេងទៀតដែលមានទីតាំងសាលារៀន ដោយមិនបានរាប់បញ្ចូលទីតាំងសាលារៀនណាដែលមានជាក់ស្តែងនៅក្នុងភូមិនោះឡើយ។

*តារាងទី២៤៖ ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងសាលារៀនដែលជិតបំផុត*

| កម្រិតអប់រំ | ចម្ងាយ (គ.ម.) | |
|---|---|---|
| | បច្ចុប្បន្ន | ៥ឆ្នាំមុន |
| មត្តេយ្យសិក្សា | ២ | ២ |
| បឋមសិក្សា | ២ | ២ |
| អនុវិទ្យាល័យ | ៣ | ៣ |
| វិទ្យាល័យ | ៨ | ៨ |
| សាកលវិទ្យាល័យ | ៣៥ | ៣៥ |

តាមតារាងទី២៤ បានបង្ហាញថា កាលពី៥ឆ្នាំមុន រហូតមកដល់បច្ចុប្បន្ន ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងសាលារៀនគឺគ្មានការប្រែប្រួលទេ ដែលពីភូមិទៅមត្តេយ្យសិក្សា និងបឋមសិក្សាមានចម្ងាយ ២គ.ម. ពីភូមិទៅអនុវិទ្យាល័យ មានចម្ងាយ ៣គ.ម. ពីភូមិទៅវិទ្យាល័យ មានចម្ងាយ ៨គ.ម. និងពីភូមិទៅសាកលវិទ្យាល័យ មានចម្ងាយ ៣៥គ.ម.។

### ២.៨.២. សេវាសង្គម

ចម្ងាយមធ្យមពីភូមិទៅទីតាំងផ្តល់សេវាសង្គម ក៏មានន័យមិនខុសគ្នាពីចម្ងាយមធ្យមពីភូមិទៅសាលារៀនដែរ ពោលគឺគិតពីចំណុចកណ្តាលនៃភូមិមួយ ទៅភូមិណាមួយផ្សេងទៀតដែលមានទីតាំងផ្តល់សេវាទាំងនោះ ដោយមិនបានរាប់បញ្ចូលទីតាំងណាដែលមានជាក់ស្តែងនៅក្នុងភូមិនោះឡើយ។

*តារាងទី២៥៖ ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងផ្តល់សេវាសង្គមដែលជិតបំផុត*

| សេវាសង្គម | ចម្ងាយ (គ.ម.) | |
|---|---|---|
| | បច្ចុប្បន្ន | ៥ឆ្នាំមុន |
| មន្ទីរពេទ្យ | ១១ | ១២ |
| មណ្ឌលសុខភាព | ៣ | ៣ |
| គ្លីនិកឯកជន | ៨ | ៩ |
| សហគមន៍ប្រើប្រាស់ទឹក/អណ្តូង | ១០ | ១០ |
| មណ្ឌលពាណិជ្ជកម្ម/ផ្សារ | ៨ | ៨ |
| ប៉ុស្តិ៍នគរបាល | ៣ | ៣ |
| ប្រៃសណីយ៍/អ៊ីនធឺណែតកាហ្វេ | ១០ | ១២ |

តារាងទី២៥ បានបង្ហាញថា កាលពី៥ឆ្នាំមុន រហូតមកដល់បច្ចុប្បន្ន ចម្ងាយប៉ាន់ស្មានជាមធ្យមនៃសេវាសង្គមខ្លះមានការប្រែប្រួល ដូចជា មន្ទីរពេទ្យ ចម្ងាយពី១២គ.ម. មក ១១គ.ម. គ្លីនិកឯកជន ពី ៩គ.ម. មក ៨គ.ម. និងប្រៃសណីយ៍/អ៊ីនធឺណែតកាហ្វេ ពី១២គ.ម. មកត្រឹម ១០គ.ក.។ ចំណែកឯសេវាសង្គមមួយចំនួនទៀតគឺមានការផ្លាស់ប្តូរទេ ដូចជា មណ្ឌលសុខភាព និងប៉ុស្តិ៍នគរបាល មានចម្ងាយ ៣ គ.ម. មណ្ឌលពាណិជ្ជកម្ម/ផ្សារ ៨គ.ម. សហគមន៍ប្រើប្រាស់ទឹក/អណ្តូង មានចម្ងាយ ១០គ.ម.។

## ២.៩. ផ្លូវគមនាគមន៍

ផ្លូវគមនាគមន៍ គឺសំដៅលើផ្លូវថ្នល់សម្រាប់ធ្វើដំណើរទៅមក។ រូបភាពខាងក្រោមនឹងបង្ហាញពីប្រវែងផ្លូវថ្នល់ដូចជា ផ្លូវដី ផ្លូវគ្រួស និងផ្លូវបេតុង ឬផ្លូវកៅស៊ូ ដែលបានស្ថាបនាក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

*រូបភាពទី៣៤៖ ការស្ថាបនាផ្លូវថ្នល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (គិតជាគីឡូម៉ែត្រ)*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣៤ បានបង្ហាញពីការស្ថាបនាផ្លូវថ្នល់នៅទូទាំងខេត្តព្រៃវែងទាំងមូល។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ (២០១៧-២០២១) រដ្ឋបាលខេត្តព្រៃវែងបានស្ថាបនាផ្លូវថ្នល់បានប្រវែង ៣.២៧៤គ.ម. ក្នុងនោះផ្លូវដីមាន ១.៣៩៥គ.ម. ផ្លូវគ្រួស ១.៣៥៧គ.ម. ផ្លូវកៅស៊ូនិងផ្លូវបេតុងមានប្រវែង ៥២២គ.ម.។

## ២.១០. សុខាភិបាល

### ២.១០.១. សេវាកម្មសុខភាព

សេវាកម្មសុខភាព គឺសំដៅលើទីតាំង ភ្នាក់ងារ និងភាពទទួលបានសេវាកម្មសុខភាពរបស់ប្រជាពលរដ្ឋ។

## ក. ទីតាំងផ្តល់សេវាកម្មសុខភាព

*រូបភាពទី៣៥៖ ចំនួនមន្ទីរពេទ្យ និងមណ្ឌលសុខភាព*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣៥ បានបង្ហាញពីចំនួនមន្ទីរពេទ្យ និងមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពដែលមាននៅទូទាំងខេត្ត។ ក្នុងនោះយើងឃើញថា មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពមានចំនួន ១១៦កន្លែង ខណៈដែលមន្ទីរពេទ្យ (មន្ទីរពេទ្យរដ្ឋ និងឯកជន) មានត្រឹមតែ ២៦កន្លែង ប៉ុណ្ណោះ។

## ខ. ភ្នាក់ងារផ្តល់សេវាកម្មសុខភាព

*រូបភាពទី៣៦៖ ចំនួនភ្នាក់ងារផ្តល់សេវាកម្មសុខភាព*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣៦ គឺជាចំនួនអ្នកផ្តល់សេវាកម្មសុខភាពនៅទូទាំងខេត្តព្រៃវែង។ តាមរូបភាពនេះ វេជ្ជបណ្ឌិតមានចំនួន ១១៥នាក់ គិលានុបដ្ឋាយិកា/ឆ្មបមានចំនួន ២៤៨នាក់ ពេទ្យមធ្យមចំនួន ២៤១នាក់ និងឆ្មបបុរាណមានចំនួន ៧នាក់។ បើគិតជាមធ្យម នៃអ្នកផ្តល់សេវាកម្មសុខភាពនៅក្នុងខេត្តនេះ គឺមានប្រហែលជា ៤៧នាក់ នៅក្នុងក្រុង ស្រុក នីមួយៗ។

### គ. អ្នកមកទទួលសេវាកម្មសុខភាព

*រូបភាពទី៣៧៖ ចំនួនអ្នកមកទទួលសេវាកម្មពីភ្នាក់ងារផ្តល់សេវាកម្មសុខភាព*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣៧ បានបង្ហាញពីចំនួនអ្នកមករកសេវាកម្មពីភ្នាក់ងារផ្តល់សេវាកម្មសុខភាព។ តាមរូបភាពនេះ យើងឃើញថា នៅតាមមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពទាំង១១៦កន្លែង មានអ្នកមករកសេវាកម្ម ឬមកព្យាបាលច្រើន រហូតដល់ ២៩៩.២១៧នាក់ ដែលប្រហែលជា ២.៥៧៩នាក់ ក្នុងមួយទីតាំង ឬ ៧នាក់ ក្នុងមួយថ្ងៃ ខណៈដែលមន្ទីរពេទ្យ (មន្ទីរពេទ្យរដ្ឋ និងឯកជន) មាន ២៥.៩៣៩នាក់ ប្រហែលជា ៨៨៩នាក់ ក្នុងមួយទីតាំង ឬ ៣នាក់ ក្នុងមួយថ្ងៃ។

## ២.១០.២. ជំងឺសំខាន់ៗ

### ក. ជំងឺគ្រុនចាញ់

*រូបភាពទី៣៨៖ ចំនួនអ្នកកើត និងស្លាប់ដោយសារជំងឺគ្រុនចាញ់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣៨ បានបង្ហាញពីចំនួនអ្នកកើត និងស្លាប់ដោយសារជំងឺគ្រុនចាញ់ៗ យើងឃើញថាមានជនរងគ្រោះសរុបចំនួន ៤៣នាក់ (ស្រី ២១នាក់) ហើយក្នុងនោះក៏មានអ្នកស្លាប់ចំនួន ១៤នាក់ (ស្រី ៦នាក់) ប្រហែលជា ៣៣% ផងដែរៗ

## ខ. ជំងឺរបេង

*រូបភាពទី៣៩៖ ចំនួនអ្នកកើត និងស្លាប់ដោយសារជំងឺរបេង*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៣៩ បានបង្ហាញពីចំនួនអ្នកកើត និងស្លាប់ដោយសារជំងឺរបេង។ យើងឃើញថា មានជនរងគ្រោះសរុបចំនួន ៨៩១នាក់ (ស្រី ៤៤៥នាក់) ហើយក្នុងនោះក៏មានអ្នកស្លាប់ចំនួន ៧៦នាក់ (ស្រី ៣៩នាក់) ប្រហែលជា ៩% ផងដែរ។

## គ. ជំងឺអេដស៍

*រូបភាពទី៤០៖ ចំនួនអ្នកកើត និងស្លាប់ដោយសារជំងឺអេដស៍តាមក្រុមអាយុ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤០ បានបង្ហាញពីការបែងចែកទៅតាមភេទ ក្រុមអាយុនៃអ្នកកើត និងស្លាប់ដោយសារជំងឺអេដស៍។ យើងឃើញថា គ្រប់ក្រុមអាយុទាំងអស់មនុស្សភេទស្រីមានអត្រាកើត និងស្លាប់ដោយសារជំងឺអេដស៍ខ្ពស់ជាងមនុស្សភេទប្រុស (លើកលែងតែក្រុមអាយុពី ១៨-២៥ និង ៦០ឆ្នាំឡើង)។ នៅទូទាំងខេត្តព្រៃវែងមានអ្នកកើតជំងឺនេះសរុប ១.៣២៩នាក់ ដែលភាគច្រើនគឺជាមនុស្សស្រីមានវ័យពី ២៦-៥៩ឆ្នាំ និងមានអ្នកស្លាប់ចំនួន ១១៩នាក់ (ស្រី ៦២នាក់)។ ក្នុងចំណោមអ្នកស្លាប់ទាំងអស់ ភាគច្រើនគឺជាមនុស្សដែលស្ថិតនៅក្នុងវ័យ ២៦-៥៩ឆ្នាំ ដែលមាន ៦៩នាក់ (ស្រី ៤១នាក់) បន្ទាប់មកគឺ ក្រុមអាយុ ០-១៧ឆ្នាំ មាន១៨នាក់ (ស្រី ១១នាក់) បន្ទាប់មកទៀតគឺ អាយុ៦០ឆ្នាំឡើងមាន ១៧នាក់ (ស្រី ៦នាក់) និងចុងក្រោយដែលមានចំនួនតិចជាងគេគឺ អាយុពី ១៨-២៥ឆ្នាំ មានចំនួន ១៥នាក់ បើធៀបទៅនឹងក្រុមអាយុផ្សេងៗទៀត។

## ២.១០.៣. ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ និងកុមារកំព្រា

### ក. ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ

*រូបភាពទី៤១៖ ចំនួនអ្នករងផលប៉ះពាល់ក្នុងគ្រួសារ និងកុមារកំព្រាមានឪពុកម្ដាយស្លាប់ដោយសារជំងឺអេដស៍*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤១ បានបង្ហាញពីចំនួនអ្នករងផលប៉ះពាល់ក្នុងគ្រួសារ និងកុមារកំព្រាដោយមានឪពុកម្ដាយស្លាប់ដោយសារជំងឺអេដស៍។ នៅក្នុងខេត្តព្រៃវែងមានអ្នកកើតជំងឺអេដស៍ ១.៣២៩នាក់ ដែលអ្នកខ្លះរស់នៅម្នាក់ឯង និងអ្នកខ្លះទៀតរស់នៅជាមួយក្រុមគ្រួសារ។ យ៉ាងណាមិញ តាមរូបភាពខាងលើបាន

បញ្ជាក់ថា មានមនុស្សចំនួន ១.៤១៣នាក់ដែលជាសមាជិកគ្រួសាររបស់អ្នកជំងឺអេដស៍ បានរងផលប៉ះពាល់ និងកំពុងរស់នៅជាមួយគ្នា។ រូបភាពនេះក៏បានបង្ហាញផងដែរថា មានកុមារចំនួន ១២៣នាក់ ដែលកំព្រា ដោយសារឪពុកម្ដាយរបស់ពួកគេស្លាប់ដោយសារជំងឺអេដស៍។

## ខ. កុមារកំព្រា

*រូបភាពទី៤២៖ ចំនួនកុមារកំព្រាក្រោមអាយុ១៨ឆ្នាំ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤២ ជាចំនួនកុមារកំព្រាក្រោមអាយុ១៨ឆ្នាំ។ តាមរូបភាពនេះបានបង្ហាញថា នៅក្នុងខេត្តព្រៃវែងមានកុមារកំព្រាសរុបចំនួន ៧៨៨នាក់ ដែលក្នុងនោះ ៦២៨នាក់ជាកុមារកំព្រាដែលមានអ្នកមើលថែត្រឹមត្រូវ ១១៣នាក់គ្មានអ្នកមើលថែត្រឹមត្រូវ និង ៤៧នាក់ទៀត គឺជាកុមារកំព្រាដែលអាចរស់នៅពឹងពាក់លើខ្លួនឯងបាន។

## ២.១១. កសិកម្ម

កសិកម្ម គឺមិនសំដៅទៅលើការដាំដុះតែម៉្យាងនោះទេ វាសំដៅលើការចិញ្ចឹមសត្វ និងការនេសាទផងដែរ។ តាមរបាយការណ៍ជំរឿនប្រជាជនឆ្នាំ២០១៩ បានបញ្ជាក់ថា សេដ្ឋកិច្ចប្រទេសកម្ពុជាបច្ចុប្បន្នបានពឹងលើវិស័យសំខាន់បីគឺៈ វិស័យកសិកម្ម ៥៣,៤% វិស័យផលិតកម្ម ឬឧស្សាហកម្ម ១៦,៦% និងវិស័យសេវាកម្ម ១២,៦%។

### ២.១១.១. ការកាន់កាប់ដីកសិកម្ម

ដីកសិកម្ម គឺសំដៅទៅលើដីដែលគ្រួសារបានកាន់កាប់ធ្វើជាម្ចាស់កម្មសិទ្ធិផ្ទាល់ខ្លួន ឬបានប្រើប្រាស់ដូចជា ដីជួលពីគេ ដីជួលឱ្យគេ ដីប្រើប្រាស់មិនគិតថ្លៃ...ជាដើម ដើម្បីប្រើប្រាស់សម្រាប់ដាំដំណាំ ឬក៏ប្រើប្រាស់សម្រាប់ការងារកសិកម្មផ្សេងៗទៀត។

*តារាងទី២៦ៈ ការកាន់កាប់ផ្ទៃដីកសិកម្មតាមគ្រួសារ*

| ផ្ទៃដីកសិកម្ម | ចំនួន | |
|---|---|---|
| | គ្រួសារ | ភាគរយ |
| គ្មានដី | ២៥.៤៩៤ | ៨,៦ |
| ក្រោម១ហិកតា | ១៣១.៤១៦ | ៤៤,៥ |
| ១-១.៩៩ហិកតា | ៧៨.៣០៤ | ២៦,៥ |
| ២-២.៩៩ហិកតា | ៣០.៩០២ | ១០,៤ |
| ៣-៣.៩៩ហិកតា | ១៥.៩១៤ | ៥,៤ |
| ៤-៤.៩៩ហិកតា | ៨.៣១១ | ២,៨ |
| ៥ហិកតាឡើង | ៥.២៤៥ | ១,៨ |
| **សរុប** | **២៩៥.៥៨៦** | **១០០** |

តារាងទី២៦ បានបង្ហាញថា នៅខេត្តព្រៃវែងគ្រួសារភាគច្រើនមានក្បាលដីកាន់កាប់សម្រាប់ធ្វើកសិកម្ម (៩១,៤%) ហើយក៏មានគ្រួសារមួយចំនួនតូច (៨,៦%) គ្មានដីប្រើប្រាស់សម្រាប់ធ្វើកសិកម្មផងដែរ ដែលពួកគាត់អាចជាគ្រួសាររស់នៅទីប្រជុំជនមានមុខរបរលក់ដូរតាមផ្ទះ លក់ដូរនៅផ្សារ ឬធ្វើការងារផ្សេងៗ។ ភាគច្រើននៃគ្រួសារទាំងនោះ (១៣១.៤១៦គ្រួសារ ស្មើ៤៤,៥%) មានដីកាន់កាប់

សម្រាប់ធ្វើកសិកម្មទំហំតិចជាង១ហិកតា ខណៈដែលគ្រួសារមានដីកសិកម្មចាប់ពី៥ហិកតាឡើងទៅ មានចំនួនតិចជាងគេ គឺត្រឹមតែ ១,៨% (៥,២៤៥គ្រួសារ) តែប៉ុណ្ណោះ។

## ២.១១.២. ប្រភេទផ្ទៃដីកសិកម្ម

ផ្ទៃដីកសិកម្មនៅប្រទេសកម្ពុជាត្រូវបានចែកដីជាពីរប្រភេទគឺ ប្រភេទដីស្ងួត និងប្រភេទដីសើម។ ចំណែកឯរដូវវិញក៏មានពីរដែរគឺ រដូវប្រាំង និងរដូវវស្សា។

*រូបភាពទី៤៣៖ ភាគរយនៃប្រភេទផ្ទៃដីកសិកម្ម*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤៣ បានបង្ហាញថា នៅខេត្តព្រៃវែងមានប្រភេទដីស្ងួតច្រើនលើសលុបរហូតដល់ទៅ ៨៥% ចំណែកឯប្រភេទដីសើមមានតែ ១៥% ប៉ុណ្ណោះ។

## ២.១១.៣. ផ្ទៃដីកសិកម្ម និងផលិតកម្ម




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤៤ បានបង្ហាញពីចំនួនផ្ទៃដីកសិកម្ម និងផ្ទៃដីផលិតកម្ម។ តាមរូបនេះយើងឃើញថា ក្នុងចំណោមផ្ទៃដីសម្រាប់ធ្វើកសិកម្មសរុប ៣៤១.៥៩៦ហិកតា ប្រជាពលរដ្ឋបានបង្កបង្កើនផលអស់ ៣៣៣.៨៨១ហិកតា ដែលស្មើនឹង ៩៨%។

## ២.១១.៤. ប្រព័ន្ធស្រោចស្រព




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤៥ បង្ហាញថា ស្រូវគឺជាដំណាំចម្បងដែលបានដាំដុះនៅលើផ្ទៃដីកសិកម្ម។ រូបនេះក៏បង្ហាញទៀតថា ដំណាំស្រូវមានប្រព័ន្ធស្រោចស្រពទំហំ ១៦២.០៧៨ហិកតា ខណៈដែលដំណាំផ្សេងៗទៀតមាន ៧.៨៨៤ហិកតា។ ទន្ទឹមនោះ ក៏នៅមានដំណាំស្រូវ ១៦០.២៤១ហិកតា និងដំណាំផ្សេងៗទៀតចំនួន ៣.៥៧៨ហិកតាទៀតគ្មានប្រព័ន្ធស្រោចស្រពផងដែរ។




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤៦ បានបង្ហាញថា ស្ទើរតែពាក់កណ្ដាលនៃផ្ទៃដីផលិតកម្មគឺគ្មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ខណៈដែលផ្ទៃដីផលិតកម្ម ៥១% មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់។

## ២.១១.៥. ការប្រើប្រាស់ជី និងថ្នាំពុលលើផ្ទៃដីផលិតកម្ម

### ក. ការប្រើប្រាស់ជីលើផ្ទៃដីផលិតកម្ម

*រូបភាពទី៤៧៖ ភាគរយនៃការប្រើប្រាស់ជីលើផ្ទៃដីផលិតកម្ម*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៤៧ បង្ហាញថា ជីគីមីត្រូវបានប្រើលើសលុបទៅលើផ្ទៃដីផលិតកម្មរហូតទៅដល់ ៩៧% ចំណែកឯជីសរីរាង្គវិញមានត្រឹមតែ ៣% ប៉ុណ្ណោះ។

### ខ. ការប្រើប្រាស់ថ្នាំពុលលើផ្ទៃដីផលិតកម្ម

*រូបភាពទី៤៨៖ ការប្រើប្រាស់ថ្នាំពុលលើផ្ទៃដីផលិតកម្ម (គិតជាហិកតា)*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

ទន្ទឹមនឹងការប្រើប្រាស់ជីទាំងពីរប្រភេទខាងលើ តាមរូបភាពទី៤៨ ក៏បានបង្ហាញនូវការប្រើប្រាស់ថ្នាំពុលលើដំណាំកសិកម្មផងដែរ។ យើងឃើញថា ផ្ទៃដីផលិតកម្មទាំងអស់ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតលើដំណាំស្រូវមានចំនួនច្រើនជាងគេ ៣២២.៣១៨ហិកតា ខណៈដែលដំណាំក្រៅពីស្រូវមាន ១១.៥៦២ហិកតា សម្រាប់ផ្ទៃដីប្រើប្រាស់ថ្នាំសម្លាប់ស្មៅវិញ ចំពោះដំណាំស្រូវមានចំនួន ២៨១.៩៦៩ហិកតា និងដំណាំមិនមែនស្រូវមានចំនួន ៤.៧០៦ហិកតា ហើយផ្ទៃដីប្រើប្រាស់ថ្នាំសម្លាប់ផ្សិតវិញគឺមានទំហំតិចជាងគេ ចំពោះដំណាំស្រូវ មានទំហំផ្ទៃដី ២៧.៧៣៩ហិកតា និងដំណាំមិនមែនស្រូវមានទំហំ ២១៩ហិកតា។

## ២.១១.៦. ការចិញ្ចឹមបសុសត្វ និងបសុបក្សី

### ក. បសុសត្វ

*តារាងទី២៧៖ ចំនួនគ្រួសារចិញ្ចឹមបសុសត្វ*

| បសុសត្វ | ចំនួនគ្រួសារ | ចំនួនបសុសត្វ |
|---|---|---|
| គោ | ១២៣.១៨៨ | ៣៦៤.០៩៥ |
| ក្របី | ៥.៧០៤ | ១៨.៩៩៨ |
| សេះ | ២០២ | ៤៥១ |
| ជ្រូក | ១៩.៥៣៣ | ៧៣.៣២៧ |
| ពពែ/ចៀម | ២២០ | ២.៥១០ |

តារាងទី២៧ បង្ហាញពីចំនួនបសុសត្វដែលបានចិញ្ចឹមតាមគ្រួសារ។ ក្នុងតារាងនេះយើងឃើញថា គោ ឈរនៅលំដាប់ខ្ពស់ទី១ គឺមានចំនួន ៣៦៤.០៩៥ក្បាល ត្រូវបានចិញ្ចឹមក្នុង ១២៣.១៨៨ គ្រួសារ (ជាមធ្យមប្រហែល៣ក្បាលក្នុងមួយគ្រួសារ) ជ្រូកស្ថិតនៅលំដាប់ទី២ មានចំនួន ៧៣.៣២៧ ក្បាល ត្រូវបានចិញ្ចឹមក្នុង ១៩.៥៣៣គ្រួសារ (ជាមធ្យមប្រហែល៤ក្បាលក្នុងមួយគ្រួសារ) លំដាប់ទី៣គឺ ក្របី ដែលមាន ១៨.៩៩៨ក្បាល ត្រូវបានចិញ្ចឹមក្នុង ៥.៧០៤គ្រួសារ (ជាមធ្យមប្រហែល៣ក្បាលក្នុងមួយគ្រួសារ) លំដាប់ទី៤គឺ ពពែ/ចៀម មាន ២.៥១០ក្បាល ត្រូវបានចិញ្ចឹមក្នុង ២២០គ្រួសារ (ជាមធ្យមប្រហែល១១ក្បាលក្នុងមួយគ្រួសារ) និងចុងក្រោយគឺ សេះ ដែលមានចំនួន ៤៥១ក្បាល ត្រូវបានចិញ្ចឹមក្នុង ២០២គ្រួសារ (ជាមធ្យមប្រហែល២ក្បាលក្នុងមួយគ្រួសារ)។

*រូបភាពទី៤៩៖ ភាគរយគ្រួសារចិញ្ចឹមបសុសត្វ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

បើនិយាយពីភាគរយនៃគ្រួសារដែលចិញ្ចឹមបសុសត្វ ធៀបទៅនឹងចំនួនគ្រួសារសរុបវិញ យើងឃើញថា គ្រួសារដែលចិញ្ចឹមគោមាន ៤១,៧% ក្របី១,៩% សេះ០,១% ជ្រូក៦,៦% និងពពែ/ចៀមមាន ០,១% នៃចំនួនគ្រួសារសរុបទូទាំងខេត្ត (រូបភាពទី៤៩)។

## ខ. បសុបក្សី

*តារាងទី២៨៖ ចំនួនគ្រួសារចិញ្ចឹមបសុបក្សី*

| បសុបក្សី | ចំនួនគ្រួសារ | ចំនួនបសុបក្សី |
|---|---|---|
| មាន់ | ២០៥.៥៤៧ | ២.៤៣៧.៤៥៨ |
| ទា | ៣៥.៣៣៦ | ១.៥៨១.៥៧៤ |
| ផ្សេងៗ | ២១០ | ១.០៦២ |

តារាងទី២៨ បង្ហាញពីចំនួនបសុបក្សីដែលបានចិញ្ចឹមតាមគ្រួសារ។ ក្នុងតារាងនេះយើងឃើញថា មាន់ មានចំនួន ២.៤៣៧.៤៥៨ក្បាល ត្រូវបានចិញ្ចឹមក្នុង ២០៥.៥៤៧គ្រួសារ (ជាមធ្យមប្រហែល ១២ក្បាលក្នុងមួយគ្រួសារ) ទា មានចំនួន ១.៥៨១.៥៧៤ក្បាល ត្រូវបានចិញ្ចឹមក្នុង ៣៥.៣៣៦គ្រួសារ (ជាមធ្យមប្រហែល៤៥ក្បាលក្នុងមួយគ្រួសារ) និងបសុបក្សីផ្សេងៗទៀតចំនួន ១.០៦២ក្បាល ត្រូវបានចិញ្ចឹមក្នុង ២១០គ្រួសារ (ជាមធ្យមប្រហែល៥ក្បាលក្នុងមួយគ្រួសារ)។

*រូបភាពទី៥០៖ ភាគរយគ្រួសារចិញ្ចឹមបសុបក្សី*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

បើនិយាយពីភាគរយនៃគ្រួសារដែលចិញ្ចឹមបសុសត្វ ធៀបទៅនឹងចំនួនគ្រួសារសរុបវិញ យើងឃើញថា គ្រួសារដែលចិញ្ចឹមមាន់មាន ៦៩,៥% ទា១២% និងបសុបក្សីផ្សេងៗទៀតមាន ០,១% នៃចំនួនគ្រួសារសរុបទូទាំងខេត្ត (រូបភាពទី៥០)។

## គ. វារីវប្បកម្ម

*តារាងទី២៩៖ ចំនួនគ្រួសារចិញ្ចឹមវារីវប្បកម្ម*

| វារីវប្បកម្ម | ចំនួនគ្រួសារ | បរិមាណ (តោន) |
|---|---|---|
| ត្រី | ៥.១០៦ | ៣៧.៦៣៤,៩ |
| បង្គារ | ១៤ | ១២,៣ |
| បង្កង | ២៦ | ១៣៧,៦ |
| ក្រពើ | ១២ | ៨,៦ |
| កង្កែប | ៧៤ | ១៥៦,៦ |
| អន្ទង់ | ១០ | ០,៧ |
| ផ្សេងៗ | ១០ | ០,៣ |

តារាងទី២៩ គឺជាចំនួនវារីវប្បកម្មដែលចិញ្ចឹមនៅតាមគ្រួសារ។ តារាងនេះបានបង្ហាញថា នៅខេត្តព្រៃវែងគ្រួសារភាគច្រើនគឺចិញ្ចឹមត្រី (៥.១០៦គ្រួសារ ទទួលផលបាន ៣៧.៦៣៤,៩តោន ដែលជាមធ្យមប្រមាណ ៧តោន ក្នុងមួយគ្រួសារ) ខណៈបង្គារ បង្កង ក្រពើ កង្កែប អន្ទង់ និងវារីវប្បកម្មផ្សេងទៀតមានតិចតួចបំផុត។

## ២.១១.៧. ទិន្នផលដំណាំ និងគោលបំណងផលិត

### ក. ទិន្នផលដំណាំ

*តារាងទី៣០៖ ចំនួនទិន្នផលនៃដំណាំសំខាន់ៗ*

| ដំណាំ | ទិន្នផល (តោន) |
|---|---|
| ស្រូវ | ៩៧០.៤៣៦ |
| ពោត | ៤៨.៣៣៤ |
| សៀង | ៣៧ |
| សណ្ដែកបាយ | ៣៣២ |
| សណ្ដែកដី | ២១០ |
| ដំឡូងមី | ២.៤០០ |
| ដំឡូងជ្វា | ២៦ |
| ល្ង | ៥០ |
| ម្រេច | ១៥ |
| ស្វាយចន្ទី | ៨១០ |
| កៅស៊ូ | ២.០១៣ |
| ចេក | ៣.៤០៣ |

តារាងទី៣០ បង្ហាញពីចំនួនទិន្នផលនៃដំណាំសំខាន់១២មុខដែលមាននៅក្នុងខេត្តព្រៃវែង។ តាមតារាងនេះ ស្រូវ គឺជាដំណាំដែលទទួលបានទិន្នផលខ្ពស់ជាងគេ មានចំនួន ៩៧០.៤៣៦តោន បន្ទាប់មកគឺ ដំណាំពោត មាន៤៨.៣៣៤តោន ចំណែកឯដំណាំម្រេចមានទិន្នផលតិចជាងគេ គឺត្រឹម ១៥តោន តែប៉ុណ្ណោះ បើធៀបទៅនឹងដំណាំទាំង១២មុខក្នុងតារាងខាងលើ។

## ខ. គោលបំណងផលិត




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តព្រៃវែងឆ្នាំ២០២១*

រូបភាពទី៥១ បង្ហាញពីគោលបំណងសំខាន់នៃការផលិតដំណាំ (ដាំដំណាំ)។ យើងឃើញថា គោលបំណងសំខាន់ **ស្រូវ** ៥៣% គឺដាំសម្រាប់បរិភោគ ខណៈដែល ៤៧% ទៀតដាំសម្រាប់លក់ **ពោត** ៥២% គឺដាំសម្រាប់បរិភោគ ខណៈដែល ៤៨% ទៀតដាំសម្រាប់លក់ **សណ្តែកបាយ** ៨០% គឺដាំសម្រាប់បរិភោគ ខណៈដែល ២០% ទៀតដាំសម្រាប់លក់ **សណ្តែកដី** ៦៧% គឺដាំសម្រាប់បរិភោគ ខណៈដែល ៣៣% ទៀតដាំសម្រាប់លក់ **ដំឡូងជ្វា** ៥០% គឺដាំសម្រាប់បរិភោគ ខណៈដែល ៥០% ទៀតដាំសម្រាប់លក់ **ល្ង** ៨០% គឺដាំសម្រាប់បរិភោគ ខណៈដែល ២០% ទៀតដាំសម្រាប់លក់ **ស្វាយចន្ទី** ៤៧% គឺដាំសម្រាប់បរិភោគ ខណៈដែល ៥៣% ទៀតដាំសម្រាប់លក់ **ចេក** ៤៣% គឺដាំសម្រាប់បរិភោគ ខណៈដែល ៥៧% ទៀតដាំសម្រាប់លក់ និង**កៅស៊ូ** ៤៤% គឺដាំសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ខណៈដែល ៥៦% ទៀតដាំសម្រាប់លក់។ ការដាំ**សណ្តែកសៀង** និង**ម្រេច** គឺក្នុងគោលបំណងសម្រាប់តែបរិភោគ ឬបម្រើសេចក្តីត្រូវការក្នុងគ្រួសារតែប៉ុណ្ណោះ វាផ្ទុយពីការដាំ**ដំឡូងមី** ដែលគោលបំណងសំខាន់គឺសម្រាប់តែលក់។

# ជំពូកទី៣

# សន្និដ្ឋាន និងអនុសាសន៍

## ៣.១. សន្និដ្ឋាន

តាមលទ្ធផលនៃការវិភាគខាងលើអាចសន្និដ្ឋានបានថាៈ ក្រៅពីកត្តាប្រជាជន គឺមានកត្តាផ្សេងទៀតដែលជះឥទ្ធិពលដល់ការរួមចំណែកក្នុងការអភិវឌ្ឍរបស់ខេត្តព្រៃវែងដូចជា ការប្រើប្រាស់ទឹកស្អាត ការប៉ះពាល់បរិស្ថាន និងអនាម័យ បញ្ហាទំនាស់ដីធ្លី អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ អសន្តិសុខសង្គម បញ្ហាគ្រឿងញៀន សេវាសុខាភិបាល និងសេវាអប់រំ។ បញ្ហាទាំងអស់នេះជាធាតុចូលយ៉ាងសំខាន់ដែលត្រូវគិតគូរវែងឆ្ងាយទៅអនាគតរហូតដល់ឆ្នាំ២០២៥ ក្នុងការអភិវឌ្ឍរបស់ខេត្តព្រៃវែង ដើម្បីផ្តល់ឱ្យប្រជាជនដែលរស់នៅទទួលបានសុខុមាលភាព និងទទួលបានសុវត្ថិភាពជីវភាពរស់នៅខ្ពស់ផងដែរ។

## ៣.២. អនុសាសន៍

ខាងក្រោមនេះជាអនុសាសន៍មួយចំនួន ដើម្បីឱ្យខេត្តព្រៃវែងមានការអភិវឌ្ឍល្អប្រសើរៈ

១. គ្រប់គ្រងនូវចំនួនប្រជាជនទាំងការចំណាក និងចំណូលស្រុកឱ្យបានច្បាស់លាស់ ព្រោះថាកត្តាប្រជាជនជាកត្តាចម្បងនៃការរៀបចំផែនការអភិវឌ្ឍផ្សេងៗនៅក្នុងមូលដ្ឋានដែលមិនអាចខ្វះបាន។

២. ជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យ តាមរយៈអាជ្ញាធរភូមិ ឃុំ/សង្កាត់ និងអង្គការក្រៅរាជរដ្ឋាភិបាល រួមទាំងការចូលរួមពីមន្ទីរអភិវឌ្ឍន៍ជនបទផងដែរ។

៣. ការដោះស្រាយទំនាស់ដីធ្លី គួរធ្វើទៅតាមបច្ចេកទេស និតិវិធីនៃច្បាប់ និងតម្លាភាព ដោយមានការសហការពីអាជ្ញាធរដែនដី និងអាជ្ញាធរដោះស្រាយទំនាស់ដីធ្លី ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានយុត្តិធម៌ពិតប្រាកដ។

៤. អាជ្ញាធរក្នុងតំបន់ត្រូវអប់រំអំពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារ ដែលនាំឱ្យមានការបែកបាក់គ្រួសារ បាត់បង់អាយុជីវិត ខាតបង់ប្រាក់កាស និងពេលវេលាសម្រាប់ប្រកបរបររកស៊ីប្រចាំថ្ងៃ ម៉្យាងទៀតវានាំឱ្យរំខានដល់អ្នកជិតខាង និងអាជ្ញាធរដើម្បីជួយដោះស្រាយទៀតផង។

៥. ការរៀបចំ និងត្រួតពិនិត្យភ្លើងសញ្ញាចរាចរណ៍ជាប្រចាំ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលអាចកើតឡើង ព្រោះតាមទិន្នន័យដែលយើងប្រមូលបានបញ្ហានេះគឺនៅមានកម្រិតខ្ពស់នៅឡើយ។

៦. សមត្ថកិច្ចគួរតែមានវិធានការឱ្យខានតែបាននូវបញ្ហាអសន្តិសុខនៅក្នុងមូលដ្ឋានរបស់ខ្លួនដូចជា ការលួច ឆក់ ប្លន់ និងឃាតកម្ម គ្រឿងញៀនផ្សេងៗជាដើម។

៧. ពង្រឹង និងពង្រីកបន្ថែមទៀតនូវការផ្តល់សេវាសុខាភិបាល និងសេវាផ្សេងៗទៀតដែលជារបស់រដ្ឋឱ្យបានល្អប្រសើរដល់ប្រជាពលរដ្ឋដែលត្រូវការ។

# តារាងទិន្នន័យ
# សង្ខេប

*តារាងទី១៖ ចំនួន និងភេទមេគ្រួសារនៅតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួន | | |
|---|---|---|---|
| | បុរសជាមេគ្រួសារ | ស្ត្រីជាមេគ្រួសារ | សរុបគ្រួសារ |
| កញ្ជ្រៀច | ១៥.០៩១ | ៣.១២០ | ១៨.២១១ |
| កំចាយមារ | ២១.១៥៩ | ៥.២៩៦ | ២៦.៤៥៥ |
| កំពង់ត្របែក | ២៧.៣០៩ | ៥.៥២៣ | ៣២.៨៣២ |
| បាភ្នំ | ១៩.៧៦០ | ៤.៥៩១ | ២៤.៣៥១ |
| ពាមជរ | ១៤.១៨៦ | ១.៩១៩ | ១៦.១០៥ |
| ពាមរក៍ | ១២.៧៧៨ | ២.៥៩០ | ១៥.៣៦៨ |
| ពារាំង | ២៦.០២៤ | ៣.៧៤០ | ២៩.៧៦៤ |
| ពោធិ៍រៀង | ១០.៦៤៨ | ១.៥៥២ | ១២.២០០ |
| ព្រៃវែង | ៦.៨២១ | ១.៧២១ | ៨.៥៤២ |
| ព្រះស្ដេច | ២៨.៥២៦ | ៤.៧៧៣ | ៣៣.២៩៩ |
| មេសាង | ២៤.៥២៥ | ៥.២៥៨ | ២៩.៧៨៣ |
| ស៊ីធរកណ្ដាល | ១៤.៥៦២ | ៣.៦៤០ | ១៨.២០២ |
| ស្វាយអន្ទរ | ២៥.៨៤៦ | ៤.៦២៨ | ៣០.៤៧៤ |
| **សរុបរួម** | **២៤៧.២៣៥** | **៤៨.៣៥១** | **២៩៥.៥៨៦** |

*តារាងទី២៖ ចំនួនស្ត្រីជាមេគ្រួសារដែលមានក្មេងអាយុក្រោម៥ឆ្នាំនៅតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ស្ត្រីជាមេគ្រួសារដែលមានក្មេងអាយុក្រោម៥ឆ្នាំ | |
|---|---|---|
| | ចំនួន | ភាគរយ |
| កញ្ច្រៀច | ៣១៥ | ១០ |
| កំចាយមារ | ៥០៦ | ១០ |
| កំពង់ត្របែក | ៧៨០ | ១៤ |
| បាភ្នំ | ៤៨៧ | ១១ |
| ពាមជរ | ២៥១ | ១៣ |
| ពាមរក៍ | ១៨៥ | ៧ |
| ពារាំង | ៤៨០ | ១៣ |
| ពោធិ៍រៀង | ១៩៣ | ១២ |
| ព្រៃវែង | ៤០៥ | ២៤ |
| ព្រះស្ដេច | ៥៤៣ | ១១ |
| មេសាង | ៧៣៦ | ១៤ |
| ស៊ីធរកណ្ដាល | ៨៨៨ | ២៤ |
| ស្វាយអន្ទរ | ៩០១ | ១៩ |
| **សរុប** | **៦.៦៧០** | **១៤** |

*តារាងទី៣៖ ចំនួនប្រជាជននៅតាមក្រុង/ស្រុក*

| ក្រុង/ស្រុក | ចំនួនប្រជាជន | | |
|---|---|---|---|
| | ប្រុស | ស្រី | សរុប |
| កញ្ជ្រៀច | ៣៥.៦១៦ | ៣៨.៩០០ | ៧៤.៥១៦ |
| កំចាយមារ | ៤៩.០០៣ | ៥១.៤០២ | ១០០.៤០៥ |
